ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅណែនាំស្តីពីការ
# អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

## មគ្គុទេសក៍ស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជា
## ប្រចាំសម្រាប់គ្រូបង្រៀន នាយកសាលា
## និងអ្នកឯកទេសអប់រំនៅកម្ពុជា

ខែមេសា ឆ្នាំ ២០២១

មាតិកា

សៀវភៅណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ....... 1

បញ្ជីពាក្យកាត់ និងអក្សរកាត់ ....... 4

១. សេចក្តីផ្តើម ....... 7

១.១ គោលដៅរួមប្រព័ន្ធ CPD ....... 7

១.២. CPD តាមសាលារៀន ....... 9

២. ដំណើរការ CPD៖ គោលការណ៍ណែនាំស្តីពីការប្រើប្រាស់ CPD សម្រាប់គ្រូបង្រៀន នាយកសាលា និង អ្នកឯកទេសអប់រំ ....... 12

២.១ ការរៀបចំផែនការសិក្សាវិជ្ជាជីវៈ ....... 12

២.២. ប្រព័ន្ធក្រេឌីត CPD ....... 13

២.៣ ទំនាក់ទំនងនិងការបន្សឹរវាងប្រព័ន្ធ CPD និងប្រព័ន្ធផ្សេងទៀត ....... 18

CPD និងប្រព័ន្ធវាយតម្លៃ ....... 19

CPD និងប្រព័ន្ធគន្លងអាជីពគ្រូបង្រៀន ....... 19

ក្រេឌីត CPD និងការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (Teacher Qualification Upgrade TQU) ... 21

CPD និងប្រព័ន្ធប្រឹក្សាគរុកោសល្យ (Mentoring system) ....... 23

៣. គោលការណ៍ណែនាំស្តីពីការគ្រប់គ្រង ....... 1

៣.១ កម្រិតនៃការទទួលខុសត្រូវ និងភារកិច្ច ....... 1

សាលារៀន គណៈកម្មការ CPD កម្រងសាលារៀន និងសហគមន៍សិក្សាវិជ្ជាជីវៈ ....... 1

ការិយាល័យ អ.យ.ក ក្រុង ស្រុក ខណ្ឌ ....... 3

មន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត ....... 3

ការិយាល័យគ្រប់គ្រង CPD (CPDMO) របស់ក្រសួងអប់រំ យុវជន និងកីឡា និងប្រព័ន្ធHRMIS ....... 4

អ្នកផ្តល់សេវា CPD ....... 5

៣.២ របហូរព័ត៌មាន CPD គន្លងអាជីពគ្រូបង្រៀន (TCP) និង HRMIS ....... 6

៤. នីតិវិធី យន្តការទទួលស្គាល់អ្នកផ្តល់សេវា និងការផ្តល់ CPD ....... 11

៤.១ គ្រឹះស្ថាន និងដំណើរការ ....... 11

.៤.១.១ ការទទួលស្គាល់គ្រឹះស្ថានផ្តល់សេវានិងការផ្តល់CPD ....... 11

៤.១.២ នីតិវិធីទទួលស្គាល់គុណភាព ....... 11

៤.៣ ការផ្តល់ការទទួលស្គាល់គុណភាពដល់គ្រូឧទ្ទេស ....... 15

៤.៤ ការផ្តល់ការទទួលស្គាល់គុណភាពដល់សេវា CPD ........ 15
៤.៥ ការអនុវត្តស្តង់ដាអប្បបរមា ........ 16
៥. ព័ត៌មាន និងការផ្សព្វផ្សាយដល់គ្រូបង្រៀន និងនាយកសាលា ........ 17
៥.១ ផ្សព្វផ្សាយអំពី CPD ........ 17
៥.២ ដំណើរការ CPD តាមប្រព័ន្ធអនឡាញ ........ 18
ឯកសារយោង ........ 19
ឧបសម្ព័ន្ធ ........ 20
១. ឧបករណ៍វាយតម្លៃតម្រូវការ CPD សម្រាប់គ្រូបង្រៀន ........ 20
២ ឧបករណ៍វាយតម្លៃតម្រូវការ CPD សម្រាប់នាយកសាលា ........ 23
៣. កម្រងស្នាដៃវិជ្ជាជីវៈ ........ 32
ពិពណ៌នាពីកម្រងស្នាដៃវិជ្ជាជីវៈ និងឧទាហរណ៍ពីខ្លឹមសារនៃកម្រងស្នាដៃវិជ្ជាជីវៈ ........ 32
ទម្រង់គំរូកម្រងស្នាដៃវិជ្ជាជីវៈជាគ្រូបមុខ រួមនឹងព័ត៌មានជាក់លាក់ដែលត្រូវបញ្ចូល ........ 35
៤. ទម្រង់គំរូនៃផែនការសិក្សាវិជ្ជាជីវៈ ........ 41
ទម្រង់គំរូនៃផែនការវិជ្ជាជីវៈ ........ 42
៥. ទម្រង់គំរូកំណត់ត្រាអាជីព ........ 44
ជីព ........ 44
៦. ទម្រង់គំរូនៃវិញ្ញាបនបត្របញ្ជាក់ពីការអភិវឌ្ឍជាប្រចាំ ........ 46
៧. ទម្រង់គំរូនៃប្រតិទិនប្រចាំឆ្នាំដែលបង្ហាញពីសេវា/ព្រឹត្តិការណ៍ CPD ........ 47
៨. ឧបករណ៍សម្រាប់ផ្តល់ការទទួលស្គាល់គុណភាពដល់អ្នកផ្តល់សេវា CPD សេវា CPD ។ល។ សម្រាប់ការិយាល័យគ្រប់គ្រង CPD ប្រើប្រាស់ ........ 49
ឧបករណ៍ដែលត្រូវបានស្នើឡើងសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពដល់អ្នកផ្តល់សេវា CPD ........ 49
ឧបករណ៍ដែលត្រូវបានស្នើឡើងសម្រាប់សេវា CPD ដែលត្រូវផ្តល់ឱ្យគ្រូបង្រៀន ........ 51
ឧបករណ៍ដែលត្រូវបានស្នើឡើងសម្រាប់សេវា CPD ដែលត្រូវផ្តល់ឱ្យនាយកសាលា ........ 54
ឧបករណ៍ដែលត្រូវបានស្នើឡើងសម្រាប់សេវា CPD ដែលត្រូវផ្តល់ឱ្យនាយកសាលាគរុកោសល្យ ........ 57
៩. ឧទាហរណ៍ដែលបង្ហាញពីការផ្តល់ក្រេឌីត CPD ........ 60
១០. សន្ទានុក្រម ........ 63
១១. តួនាទីរបស់ការិយាល័យគ្រប់គ្រង CPD ........ 66

# បញ្ជីពាក្យកាត់ និងអក្សរកាត់

| ពាក្យកាត់ | ភាសាអង់គ្លេស | ភាសាខ្មែរ |
|---|---|---|
| ACC | Accreditation Committee of Cambodia | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា |
| ASEAN | Association of South East Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| AMS | ASEAN Member State | រដ្ឋជាសមាជិកអាស៊ាន |
| BA | Bachelor of Arts | បរិញ្ញាបត្រ |
| B Ed | Bachelor of Education | បរិញ្ញាបត្រអប់រំ |
| CPD | Continuous Professional Development | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |
| CPDMO | Continuous Professional Development Management Office | ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |
| DoPers | Department of Personnel | នាយកដ្ឋានបុគ្គលិក |
| DoE | District Office of Education | ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ |
| DP | Development Partner | ដៃគូអភិវឌ្ឍន៍ |
| ESP | Education Strategic Plan | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| GPE 3 | General Partnership for Education phase 3 programme | កម្មវិធីភាពជាដៃគូសកលសម្រាប់ការអប់រំដំណាក់កាលទី ៣ |
| HRMIS | Human Resources Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស |
| ICT | Information and Communications Technologies | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |
| INSET | In-Service Teacher Education and Training | វិក្រឹតការគ្រូបង្រៀន |
| MA | Master of Arts | បរិញ្ញាបត្រជាន់ខ្ពស់ |
| M&E | Monitoring and Evaluation | ការពិនិត្យតាមដាន និងវាយតម្លៃ |

| | | |
|---|---|---|
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MOOC | Massive Open Online Course | វគ្គបណ្ដុះបណ្ដាលអនឡាញបើកទូលាយ |
| NGO | Non-Governmental Origination | អង្គការក្រៅរដ្ឋាភិបាល |
| NIE | National Institute of Education | វិទ្យាស្ថានជាតិអប់រំ |
| NQF | National Qualifications Framework | ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា |
| OECD | Organisation for Economic Co-operation and Development | អង្គការសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច |
| PoE | Provincial Office of Education | មន្ទីរអប់រំរាជធានីខេត្ត |
| PhD | Doctor of Philosophy (Doctorate) | សញ្ញាបត្របណ្ឌិត |
| PLC | Professional Learning Community | សហគមន៍សិក្សាវិជ្ជាជីវៈ |
| PLP | Professional Learning Plan | ផែនការសិក្សាវិជ្ជាជីវៈ |
| PTEC | Phnom Penh Teacher Education College | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| PTTC | Provincial Teacher Training Centre | សាលាគរុកោសល្យ និងវិក្រឹតការខេត្ត |
| QA | Quality Assurance | ការធានាគុណភាព |
| RTTC | Regional Teacher Training Centre | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ |
| SBM | School-Based Management | ការគ្រប់គ្រងតាមសាលារៀន |
| SEIP | Secondary Education Improvement Project | គម្រោងកែលម្អការអប់រំមធ្យមសិក្សា |
| STEPCam | Strengthening Teacher Education Programmes in Cambodia | កម្មវិធីពង្រឹងការអប់រំគ្រូបង្រៀននៅកម្ពុជា |
| TCP | Teacher Career Pathways | គន្លងអាជីពគ្រូបង្រៀន |
| TD | Technical Department | នាយកដ្ឋានបច្ចេកទេស |

| | | |
|---|---|---|
| TEI | Teacher Education Institution | គ្រឹះស្ថានអប់រំគ្រូបង្រៀន |
| TEPS | Teacher Education Provider Standards | ស្តង់ដាសម្រាប់អ្នកផ្តល់សេវាអប់រំគ្រូបង្រៀន |
| TPAP | Teacher Policy Action Plan | ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន |
| TTD | Teacher Training Department | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| TQU | Teacher Qualifications Upgrade | ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន |
| TVET | Technical and Vocational Education and Training | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UNESCO | United Nations Educational, Scientific and Cultural Organisation | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃ សហប្រជាជាតិ |
| UNICEF | United Nations Children’s Fund | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| USESDP-2 | Upper Secondary Education Sector Development Programme - 2 | គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី ២ |

# ១. សេចក្ដីផ្ដើម

សៀវភៅណែនាំស្ដីពី CPD នេះ ត្រូវបានតាក់តែងឡើង ក្នុងគោលបំណងផ្ដល់ភាពងាយស្រួលដល់គ្រប់ភាគីពាក់ព័ន្ធ ចូលរួមអនុវត្ត CPD សម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំនៅកម្ពុជា។[1] សៀវភៅណែនាំនេះត្រូវបានរៀបចំឡើង ដើម្បីជួយអ្នកគ្រប់គ្រង អ្នកផ្ដល់សេវា CPD និងបុគ្គលិកអប់រំក្នុងការរៀបចំផែនការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ និងទទួលខុសត្រូវលើការវាយតម្លៃលទ្ធផលការងារប្រចាំឆ្នាំ ។

បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា កំពុងធ្វើកំណែទម្រង់ដំណើរការកសាងសមត្ថភាពបុគ្គលិកអប់រំ រួមនឹងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធ CPD ប្រកបដោយនវានុវត្តន៍។ ដូច្នេះ សៀវភៅណែនាំនេះ រៀបចំឡើងសម្រាប់ធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីឆ្លុះបញ្ចាំងពីដំណើរការវិវឌ្ឍនៃប្រព័ន្ធ CPD ។

## ១.១ គោលដៅរួមប្រព័ន្ធ CPD

### និយមន័យ CPD

នៅក្នុងប្រទេសភាគច្រើន ការអប់រំគ្រូបង្រៀន គឺជាដំណើរការដែលធ្វើជាប់ជាប្រចាំ ពោលគឺចាប់ផ្ដើមនៅពេលដែលគរុសិស្សចូលរៀននៅក្នុងកម្មវិធីអប់រំដំបូងសម្រាប់គ្រូ។ ក្រោយពីបញ្ចប់ការបណ្ដុះបណ្ដាលដំបូងដោយជោគជ័យ និងទទួលបានអាជ្ញាប័ណ្ណសម្រាប់អនុវត្តវិជ្ជាជីវៈបង្រៀនក្លាយជាគ្រូដែលមានសមត្ថភាព គ្រូបង្រៀនត្រូវបន្តការអប់រំវិជ្ជាជីវៈរបស់ខ្លួន ពេញមួយជីវិត។[2] លក្ខខណ្ឌនេះគឺជាលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌនានាដែលតម្រូវឱ្យគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំក្លាយជាអ្នករៀនសូត្រពេញមួយជីវិត សម្រាប់ផ្ដល់អត្តសញ្ញាណជាបុគ្គលិកអប់រំប្រកបដោយវិជ្ជាជីវៈ ។

អ្វីទៅដែលហៅថា CPD សម្រាប់គ្រូបង្រៀន? ក្របខណ្ឌ និងផែនការសកម្មភាពស្ដីពី CPD ឱ្យនិយម

---

[1] ដោយសារតែការលំបាក និងភាពស្មុគស្មាញក្នុងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធមួយដែលតម្រូវឱ្យមានការផ្លាស់ប្ដូរយ៉ាងច្រើននៃវប្បធម៌ និងការអនុវត្តវិជ្ជាជីវៈជាប្រចាំ ការអនុវត្តប្រព័ន្ធ CPD កំពុងធ្វើឡើងដោយប្រើប្រាស់អភិក្រមជាដំណាក់កាល។ នៅក្នុងដំណាក់កាលទី ១ (២០២១-២០២៥) មានការផ្ដោតការយកចិត្តទុកដាក់ជាចម្បងលើ CPD សម្រាប់គ្រូបង្រៀន និងនាយកសាលា។ CPD សម្រាប់អ្នកឯកទេសអប់រំ និង CPD សម្រាប់នាយកសាលាផ្សេងៗទៀត នឹងត្រូវបញ្ចូល ទៅក្នុងដំណាក់កាលទី ២ អមជាមួយនឹងការបន្តអភិវឌ្ឍន៍ប្រព័ន្ធ CPD សម្រាប់គ្រូបង្រៀន ដូចជា ការដាក់ឱ្យអនុវត្តនូវ CPD ដែលចូលរួមដោយខ្លួនឯង ជាដើម។ នេះតម្រូវឱ្យមានការកំណត់បុរេលក្ខខណ្ឌមួយចំនួន ដូចជា ការអភិវឌ្ឍស្តង់ដារវិជ្ជាជីវៈសម្រាប់អ្នកឯកទេសអប់រំ ដែលបច្ចុប្បន្ននេះនៅមិនទាន់មាននៅឡើយ។ ការអនុវត្តអភិក្រមជាដំណាក់កាលៗបែបនេះ មិនគួររារាំងនាយកសាលា ឬអ្នកឯកទេសអប់រំមិនឱ្យចូលរួមក្នុងសកម្មភាព CPD មុនដំណាក់កាលទី ២ នៃដំណើរការនេះឡើយ។ ការប្រើប្រាស់អភិក្រមបែបនេះគ្រាន់តែឆ្លុះបញ្ចាំងពីអាទិភាពរបស់ជាតិតែប៉ុណ្ណោះ ក្នុងគោលបំណងធានាយ៉ាងណាឱ្យបុគ្គលិកសិក្សាទាំងអស់ទទួលបានការទទួលបាននូវចំណេះដឹង និងជំនាញវិជ្ជាជីវៈដែលចាំបាច់ សម្រាប់ការបំពេញការងាររបស់ពួកគេ។

[2] បើទោះជាការផ្ដល់អាជ្ញាប័ណ្ណឱ្យគ្រូបង្រៀននៅមិនទាន់អនុវត្តក្នុងប្រទេសកម្ពុជាក៏ដោយ នេះគឺជាយន្តការដែលចាំបាច់នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីឈានទៅលើកកម្ពស់វិជ្ជាជីវៈបុគ្គលិកអប់រំ ក៏ដូចជា បង្កើនគុណភាពនៃការបង្រៀន។ នៅតាមប្រទេសជាច្រើន ការចូលរួមនៅក្នុង CPD ដែលធ្វើជាទៀងទាត់ប្រកបដោយអត្ថន័យ គឺជាលក្ខខណ្ឌមួយ ដើម្បីឱ្យគ្រូបង្រៀនអាចទទួលបាន និងរក្សាអាជ្ញាប័ណ្ណបង្រៀនរបស់ពួកគេ។

ន័យ CPD នៅកម្ពុជាថាជា "ការបណ្តុះបណ្តាលឯកទេស ការអប់រំក្នុងប្រព័ន្ធនិងក្រៅផ្លូវការ ឬការសិក្សាវិជ្ជាជីវៈកម្រិតខ្ពស់ជាច្រើនប្រភេទ ដែលមានគោលបំណងជួយឱ្យគ្រូបន្ទុកថ្នាក់ និងគ្រូឯកទេស និងនាយកសាលា បង្កើនចំណេះដឹង ជំនាញ សមត្ថភាព និងប្រសិទ្ធភាពវិជ្ជាជីវៈរបស់ពួកគេ" (ទំព័រទី ៨)។ ការអភិវឌ្ឍវិជ្ជាជីវៈគួរតែ៖

- ធ្វើឡើងជាប្រចាំ
- អនុវត្តក្រោមស្វ័យភាព និងការគ្រប់គ្រង របស់អ្នកសិក្សាដោយខ្លួនឯង
- អនុវត្តផ្អែកតាមតម្រូវការ និងស្ថានភាពអភិវឌ្ឍន៍បច្ចុប្បន្នរបស់បុគ្គលម្នាក់ៗ
- កំណត់ពីលទ្ធផលការរៀនសូត្រ និងអភិវឌ្ឍវិជ្ជាជីវៈឱ្យបានច្បាស់លាស់ ដើម្បីបំពេញទៅតាមតម្រូវការរបស់បុគ្គល និងអង្គភាព
- វាយតម្លៃលើការរៀនសូត្រ និងអភិវឌ្ឍវិជ្ជាជីវៈ បន្ថែមពីលើការរៀបរាប់សកម្មភាពផ្សេងៗ
- ចាត់ទុកថាជាផ្នែកមួយដ៏សំខាន់នៃជីវិតវិជ្ជាជីវៈ និងជីវិតផ្ទាល់ខ្លួន មិនមែនត្រឹមតែជាសកម្មភាពបន្ថែមដែលធ្វើក៏បាន មិនធ្វើក៏បាននោះឡើយ (Marchington និង Wilkinson, 2009: 377)។

CPD អាចធ្វើឡើងតាមបែបផែនច្រើនយ៉ាង ជាអាទិ៍ សិក្ខាសាលា វគ្គបំប៉ន ការបណ្តុះបណ្តាល សន្និសីទ ព្រឹត្តិការណ៍ផ្សេងៗ កម្មវិធីសិក្សាតាមប្រព័ន្ធអនឡាញ និងសហគមន៍សិក្សាវិជ្ជាជីវៈ និងសកម្មភាពដែលចូលរួមដោយខ្លួនឯងទាំងស្រុង ដូចជា ការអានអត្ថបទស្រាវជ្រាវវិជ្ជាជីវៈ ការសង្កេតមើលការបំពេញការងាររបស់សហការី ការផ្តល់ប្រឹក្សាគរុកោសល្យ និងការបង្វឹក ការស្រាវជ្រាវនៅក្នុងថ្នាក់រៀន ឬការស្រាវជ្រាវខ្នាតតូច ការចូលរួមនៅក្នុងសន្និសីទ ឬសិក្ខាសាលា ការរក្សាទិនានុប្បវត្តិ ឬសៀវភៅកត់ត្រាពីអ្វីដែលបានរៀន ដើម្បីឆ្លុះបញ្ចាំងការអនុវត្តនៅក្នុងថ្នាក់រៀន ការអានអត្ថបទព័ត៌មានករណីសិក្សាដែលពាក់ព័ន្ធ ការស្តាប់ podcasts និងព័ត៌មានថ្មីៗអំពីឧស្សាហកម្មអ្វីមួយ ការធ្វើទស្សនកិច្ចសិក្សាសង្កេតមើលបទពិសោធន៍នៅតាមសាលារៀនដទៃទៀត។ល។

សកម្មភាពដូចបានរៀបរាប់ខាងលើនេះមានគោលដៅលើកកម្ពស់ចំណេះដឹង និងសមត្ថភាពផ្ទាល់ខ្លួន និងវិជ្ជាជីវៈរបស់បុគ្គលម្នាក់ដែលផ្តល់លទ្ធភាពឱ្យពួកគេអាចបន្តបង្កើនជំនាញ ស្របទៅតាមគោលដៅរបស់ស្ថាប័ន គោលដៅវិជ្ជាជីវៈ និងគោលដៅផ្ទាល់ខ្លួន។

ប្រព័ន្ធ CPD ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់វិជ្ជាជីវៈ និងគុណភាពរបស់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ព្រមទាំងគុណភាពស្តង់ដានៃការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងគុណវុឌ្ឍិរបស់ពួកគេ។ ការចូលរួមនៅក្នុង CPD មិនប៉ះពាល់ដល់គុណភាពរបស់គ្រូ ឬការអប់រំ និងមិនប៉ះពាល់ដល់ការសិក្សារបស់សិស្សទេ។ ដូច្នេះ គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ មិនត្រូវទុកការបង្រៀន និងកាតព្វកិច្ចវិជ្ជាជីវៈដទៃទៀតចោល ដើម្បីឆ្លៀតពេលទៅចូលរួមនៅក្នុងសកម្មភាព CPD នោះឡើយ។

គោលនយោបាយ CPD ចែងពីសិទ្ធិ និងកាតព្វកិច្ចរបស់គ្រូ ដោយកំណត់ឱ្យពួកគេចូលរួមនៅក្នុងសកម្មភាព CPD ចំនួន ១០០ ម៉ោងក្នុងមួយឆ្នាំ។ នេះស្មើនឹងប្រហែលជា ៣ ម៉ោងក្នុងមួយសប្តាហ៍នៅក្នុងមួយឆ្នាំសិក្សា។ ក្របខណ្ឌ CPD ផ្តល់អនុសាសន៍ឱ្យគ្រូចំណាយពេលមិនបង្រៀន ៥ ថ្ងៃក្នុងមួយឆ្នាំ សម្រាប់ចូលរួមសកម្មភាព CPD ដែលស្មើនឹង ៤០ ម៉ោង។ នេះមានន័យថា ពួកគេចាំបាច់ត្រូវចំណាយពេលផ្ទាល់ខ្លួន ៦០ ម៉ោងទៀតសម្រាប់ចូលរួមនៅក្នុងសកម្មភាព CPD ទើបអាចបាន ១០០ ម៉ោង។ នៅក្នុងការអនុវត្តជាក់ស្តែង បន្ទុកការងាររបស់គ្រូបង្រៀននៅកម្ពុជា ផ្តល់លទ្ធភាពឱ្យគ្រូបង្រៀនភាគច្រើនចូលរួមនៅក្នុងសកម្មភាព CPD យ៉ាងហោចណាស់ ៣ ម៉ោង ក្នុងមួយសប្តាហ៍ ដោយប្រើប្រាស់ម៉ោងនៅក្នុងកិច្ចសន្យាការងាររបស់ពួកគេ។ ឧទាហរណ៍ គ្រូបឋមសិក្សាមិនបង្រៀននៅថ្ងៃព្រហស្បតិ៍សប្តាហ៍ទីបួននៃខែនីមួយៗ ដែលជាថ្ងៃបម្រុងសម្រាប់កិច្ចប្រជុំបច្ចេកទេស កិច្ចប្រជុំរបស់សហគមន៍សិក្សាវិជ្ជាជីវៈ ជួយសិស្សរៀនយឺត។ល។ ដែលជាឱកាសផ្តល់លទ្ធភាពឱ្យគ្រូបឋមសិក្សាចូលរួមនៅក្នុង CPD រយៈពេល ៣ ម៉ោងនៅក្នុងអំឡុងពេលនេះ។ គ្រូមធ្យមសិក្សាបឋមភូមិ បង្រៀន ១៨ម៉ោង និងគ្រូមធ្យមសិក្សាទុតិយភូមិបង្រៀន១៦ម៉ោង ដែលផ្តល់លទ្ធភាពឱ្យពួកគេមានពេល ៣ ម៉ោងក្នុងមួយសប្តាហ៍ ដើម្បីចូលរួមនៅក្នុងសកម្មភាព CPD។ ក្នុងករណីដែលគ្រូបង្រៀនពីរវេន នៅតាមសាលារៀនដែលជួបប្រទះនឹងការខ្វះគ្រូ វាអាចប៉ះពាល់ដល់ការចូលរួមក្នុងសកម្មភាព CPD ឱ្យបាន ៣ ម៉ោង ជារៀងរាល់សប្តាហ៍ នៅក្នុងម៉ោងបំពេញការងារដែលត្រូវបានកំណត់នៅក្នុងកិច្ចសន្យារបស់ពួកគេ។ បន្ថែមលើកាតព្វកិច្ចចូលរួមនៅក្នុង CPD ១០០ ម៉ោងក្នុងមួយឆ្នាំ គ្រូបង្រៀនដែលមានបំណងចង់ចូលរួមនៅក្នុង CPD ដើម្បីទទួលបានក្រេឌីត CPD បន្ថែម ត្រូវបានលើកទឹកចិត្តឱ្យចំណាយពេលចុងសប្តាហ៍ និងវិស្សមកាល សម្រាប់ចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈ។

## ១.២. CPD តាមសាលារៀន

ដូចដែលយើងបានឃើញកន្លងមកហើយ មានការអនុវត្ត CPD ជាច្រើនទម្រង់ផ្សេងៗគ្នាសម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ក្រៅតែពីសិក្ខាសាលាដែលធ្លាប់តែរៀបចំកន្លងមក ឬវគ្គវិក្រឹតការដែលរៀបចំនៅក្នុងសាលា។ បច្ចុប្បន្ននេះ ភស្តុតាងជាច្រើនបង្ហាញថា CPD ដែលល្អបំផុត គឺជា CPD ដែលមានទម្រង់ជាការអនុវត្ត និងឆ្លុះបញ្ចាំង ជា CPD ដែលធ្វើឡើងក្នុងសាលារៀន និងភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងដំណើររៀន និងបង្រៀន។ ជារឿយៗសិក្ខាសាលា និងវគ្គបំប៉នដែលធ្លាប់ធ្វើកន្លងមក តម្រូវឱ្យគ្រូចេញទៅខាងក្រៅថ្នាក់ ដោយពុំបានធ្វើឱ្យប្រសើរនូវការបំពេញការងាររបស់ពួកគេនៅក្នុងថ្នាក់រៀននោះឡើយ ព្រោះថា សិក្ខាសាលា និងវគ្គបំប៉នទាំងនេះពុំបានឆ្លើយតបចំពោះបញ្ហាប្រឈម ដែលគ្រូបង្រៀនម្នាក់ៗជួបប្រទះនៅក្នុងការបង្រៀនទៅតាម*បរិបទជាក់ស្តែង* ដូច្នេះសកម្មភាពទាំងនេះផ្តល់នូវផលវិជ្ជមានតិចតួចតែប៉ុណ្ណោះ។ CPD សម្រាប់គ្រូបង្រៀន "ត្រូវរៀបចំយ៉ាងណា ដើម្បីឱ្យគ្រូអាចផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹង CPD នេះ ចេញពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ និងផ្តល់ឱកាសឱ្យគ្រូបង្រៀនអាចយកចំណេះដឹងដែលទទួលបានពី CPD ទៅសាកល្បង និងធ្វើការឆ្លុះបញ្ចាំង។ អ្នកចូលរួមនៅក្នុងសកម្មភាព CPD ត្រូវយកទ្រឹស្តី

ដែលទទួលបានទៅប្រើប្រាស់ជាមួយនឹងសិស្សក្នុងបរិបទជាក់ស្តែង ដើម្បីឱ្យពួកគេចេះចាំស្ទាត់ខ្លឹមសារដែលពួកគេបានរៀន" (Gathumbi et al., 2013: 8)។ ដូចគ្នានេះដែរ CPD សម្រាប់នាយកសាលា អាចធ្វើទៅបានប្រកបដោយប្រសិទ្ធភាពបំផុត នៅពេលដែល CPD នេះ ផ្តោតលើកន្លែងធ្វើការរបស់ពួកគេ និងផ្តល់ឱកាសឱ្យមានបន្តឆ្លុះបញ្ចាំងលើស្ថានភាពជាក់ស្តែងនៅក្នុងសាលារៀន និងដោះស្រាយស្ថានភាពដែលនាយកសាលាជួបប្រទះនៅក្នុងការងារដឹកនាំ និងគ្រប់គ្រងសាលារៀនប្រចាំថ្ងៃ។ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់អ្នកឯកទេសអប់រំ អាចធ្វើឡើងនៅក្នុងសាលារៀន ឬនៅកន្លែងធ្វើការមួយផ្សេងទៀត អាស្រ័យលើប្រធានបទ និងនៅកន្លែងបំពេញការងាររបស់អ្នកឯកទេសអប់រំ។

បច្ចុប្បន្ន នៅក្នុងការអប់រំគ្រូ និងការអនុវត្ត CPD មានការគូសបញ្ជាក់ពីតួនាទីនៃការឆ្លុះបញ្ចាំងនៅគ្រប់កម្រិតទាំងអស់។ គ្រូបង្រៀន នាយកសាលា អ្នកឯកទេសអប់រំ ឬគរុសិស្ស ត្រូវបានលើកទឹកចិត្តឱ្យធ្វើការឆ្លុះបញ្ចាំង និងត្រូវឆ្លុះបញ្ចាំងពីការអនុវត្តផ្ទាល់ខ្លួនដោយផ្សារភ្ជាប់ទ្រឹស្តី បទពិសោធន៍ ទៅនឹងការអនុវត្តនៅក្នុងថ្នាក់រៀន ឬអង្គភាពការងាររបស់ខ្លួន ហើយត្រូវបន្តធ្វើបែបនេះឱ្យបានជាប់ជាប្រចាំ។

ការអនុវត្ត CPD នៅប្រទេសកម្ពុជាផ្តោតទៅលើសកម្មភាព ០២ ទម្រង់ ៖

- CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ សំដៅលើការរៀនសូត្រ វគ្គបំប៉ន បណ្តុះបណ្តាលក្នុងប្រព័ន្ធ ឬសកម្មភាព CPD ដទៃទៀតដែលផ្តល់ដោយអ្នកផ្តល់សេវា CPD ដែលបានទទួលការទទួលស្គាល់គុណភាព ដូចជា គ្រឹះស្ថានអប់រំគ្រូ ឬដៃគូអភិវឌ្ឍន៍ និងនាយកដ្ឋានជំនាញណាមួយរបស់ក្រសួងអប់រំ យុវជន និងកីឡាដោយសហការណ៍ជាមួយគ្រឹះស្ថានអប់រំគ្រូ
- CPD ដែលចូលរួមដោយខ្លួនឯង សំដៅលើសកម្មភាព CPD ដែលបុគ្គលិកអប់រំធ្វើឡើងដោយខ្លួនឯង ដោយពុំមានការគាំទ្រជាផ្លូវការពីអ្នកផ្តល់សេវា CPD ដែលបានទទួលការទទួលស្គាល់គុណភាព ប៉ុន្តែស្ថិតនៅក្នុងវិសាលភាពក្របខណ្ឌ CPDដែរ។[3]

ការចូលរួមនៅក្នុង CPD សុទ្ធតែអាចទទួលបានមកវិញនូវក្រេឌីត CPD។[4] បច្ចុប្បន្នប្រព័ន្ធ CPD នឹងដាក់ឱ្យអនុវត្តជាជំណាក់ៗ ចាប់ផ្តើមពី CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់។

---

[3] បច្ចុប្បន្ននេះប្រព័ន្ធ CPD កំពុងដាក់ឱ្យអនុវត្ត ដោយប្រើប្រាស់អភិក្រមជាជំណាក់កាលៗ ចាប់ផ្តើមពី CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់តទៅក្នុងឆ្នាំ ២០២១។ CPD ចូលរួមដោយខ្លួនឯង នឹងត្រូវអនុវត្តក្នុងឆ្នាំ ២០២៥។

[4] ក្របខណ្ឌ និងផែនការសកម្មភាព CPD លើកឡើងពីប្រព័ន្ធក្រេឌីត CPD "កូនកាត់" ពោលគឺក្រេឌីត CPD សម្រាប់ការសិក្សាជំឡើងគុណវុឌ្ឍិ និងក្រេឌីត CPD សម្រាប់អាជីពប៉ុន្តែមិនសម្រាប់ការសិក្សាជំឡើងគុណវុឌ្ឍិទេ (ទំព័រទី ១៧)។ ក្នុងនោះ CPD ក្នុងទម្រង់ជាការសិក្សាជំឡើងគុណវុឌ្ឍិ សំដៅលើ CPD ដែលផ្តល់ដោយគ្រឹះស្ថានអប់រំគ្រូ ឬគ្រឹះស្ថានឧត្តមសិក្សា ដែលនាំឱ្យមានការផ្តល់ក្រេឌីតទៅតាមវគ្គសិក្សា (ក្នុងក្របខ័ណ្ឌលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន) ហើយ CPD មិនសម្រាប់ការសិក្សាជំឡើងគុណវុឌ្ឍិ អាចជាប្រភេទ CPD ដែលធ្វើនៅតាមសាលារៀន សាលាកម្រង ឬដែលផ្តល់ដោយគ្រឹះស្ថានអប់រំគ្រូបង្រៀន ឬក្រសួងអប់រំ យុវជន និងកីឡា។

## CPD មានរចនាសម្ព័ន្ធច្បាស់លាស់ (Structured CPD)

CPD មានរចនាសម្ព័ន្ធច្បាស់លាស់ រួមមាន សកម្មភាពអនុវត្តដែលផ្តល់ដោយអ្នកផ្តល់សេវា CPD ដែលមានការទទួលស្គាល់គុណភាព មានការជួបគ្នាផ្ទាល់ក្នុងបរិមាណមួយជាក់លាក់។ សកម្មភាពដែលជួបមុខផ្ទាល់ អាចធ្វើឡើងជាទម្រង់សិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គបំប៉ន សកម្មភាពស្រាវជ្រាវជាក្រុម ឬសកម្មភាពដទៃទៀត។ អ្នកសិក្សាចូលរួមសកម្មភាពជួបផ្ទាល់មួយម៉ោង ត្រូវធ្វើស្វ័យសិក្សាយ៉ាងហោចណាស់ ២ ម៉ោងបន្ថែម។ ដោយសារតែ CPD គឺជាដំណើរការដែលមានលក្ខណៈសកម្ម ពោលគឺគ្រូបង្រៀនជាចំណុចកណ្តាលនៃការអភិវឌ្ឍខ្លួនឯង សូម្បីតែ CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ក៏តម្រូវឱ្យមានការធ្វើស្វ័យសិក្សាក្នុងបរិមាណមួយដ៏ច្រើនផងដែរ និងតម្រូវឱ្យគ្រូបង្រៀន ឬនាយកសាលាបង្ហាញថា ពួកគេពិតជាបានចូលរួមនៅក្នុងដំណើរការ CPD ពិតប្រាកដមែន ដោយពួកគេត្រូវបង្ហាញភស្តុតាងបញ្ជាក់ថា ពួកគេពិតជាបានយកមេរៀនដែលទទួលបាន ទៅប្រើប្រាស់នៅក្នុងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួននៅក្នុងថ្នាក់រៀន និងនៅក្នុងសាលារៀន ដែលជាការឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងទ្រឹស្តី និងការអនុវត្ត និងពីរបៀបដែលការសិក្សាអាចជួយឱ្យពួកគេធ្វើឱ្យការបង្រៀន និងការដឹកនាំកាន់តែមានភាពល្អប្រសើរ។ សម្រាប់ព័ត៌មានបន្ថែមអំពីការផ្តល់ក្រេឌីត CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ សូមមើលផ្នែក ២.២។

## CPD ដោយខ្លួនឯង (ស្វ័យ CPD ឬ Self-directed CPD)

CPD ដែលចូលរួមដោយខ្លួនឯង ធ្វើឡើងផ្អែកទៅតាមធាតុចូល និងលក្ខខណ្ឌតម្រូវដែលគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំម្នាក់ៗស្វែងរកដោយខ្លួនឯង ដោយមិនប្រើប្រាស់សេវារបស់អ្នកផ្តល់សេវា CPD ។ ធាតុចូលនេះរួមមាន វគ្គបណ្តុះបណ្តាលអនឡាញបើកទូលាយ MOOC ការចូលរួម និងការបង្ហាញស្នាដៃស្រាវជ្រាវផ្ទាល់ខ្លួននៅក្នុងសន្និសីទ ឬសកម្មភាពសិក្សាវិជ្ជាជីវៈដទៃទៀត ការចូលរួមនៅក្នុងការស្រាវជ្រាវ ការអានឯកសារស្រាវជ្រាវវិជ្ជាជីវៈក្នុងទម្រង់ជាព្រឹត្តបត្រស្រាវជ្រាវ ឬសៀវភៅ ការស្រាវជ្រាវ និងបោះពុម្ពផ្សាយអត្ថបទអ្វីមួយជាដើម។ល។ ក្នុងពេលឆាប់ៗនេះនឹងមានការផ្សព្វផ្សាយបញ្ជីប្រភពធាតុចូល ដែលត្រូវបានទទួលស្គាល់ដោយការិយាល័យគ្រប់គ្រង CPD ក្រោយពេលដែលប្រព័ន្ធផ្តល់ក្រេឌីត CPD ដល់ CPD ដែលចូលរួមដោយខ្លួនឯង ចាប់ផ្តើមដំណើរការ។

ការធ្វើស្វ័យ CPD ពីប្រភពមិនទាន់មានការទទួលស្គាល់គុណភាព ក៏អាចទទួលបានជាក្រេឌីតផងដែរ ហើយគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ចាំបាច់ត្រូវដាក់សំណើសុំការទទួលស្គាល់គុណភាពទៅការិយាល័យគ្រប់គ្រង CPD (CPDMO) លើប្រភព CPD ដែលខ្លួនបានប្រើប្រាស់។

ចំពោះការធ្វើស្វ័យ CPD ពីប្រភព CPD ណាមួយ ក្នុងរយៈពេលមួយម៉ោង អ្នកចូលរួមត្រូវធ្វើស្វ័

យសិក្សាលើកិច្ចការអនុវត្តយ៉ាងហោចណាស់ ២ ម៉ោងបន្ថែម។ គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំ ត្រូវបង្ហាញឱ្យឃើញថាពួកគេពិតជាបានចូលរួមយ៉ាងសកម្មក្នុងដំណើរការ CPD តាមរយៈការផ្តល់ជាភស្តុតាងបញ្ជាក់ថា ពិតជាបានយកទៅប្រើប្រាស់នៅក្នុងការអនុវត្តវិជ្ជាជីវៈនៅក្នុងថ្នាក់រៀន សាលារៀន និងត្រូវធ្វើការឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងទ្រឹស្តី ការអនុវត្ត និងបង្ហាញពីរបៀបការសិក្សា ដែលជួយឱ្យការបង្រៀនកាន់តែល្អប្រសើរជាងមុន។ សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបទទួលបានក្រេឌីតពី CPD តាមរយៈស្វ័យសិក្សា សូមមើលផ្នែក ២.២។

## ២. ដំណើរការ CPD៖ គោលការណ៍ណែនាំស្តីពីការប្រើប្រាស់ CPD សម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ

CPD គឺជាដំណើរការមួយដ៏សកម្ម ពោលគឺអ្នកចូលរួមអនុវត្តត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចសំខាន់ៗនៃខ្លឹមសារដែលត្រូវយកទៅអនុវត្តក្នុងការបង្រៀននិងរៀន សំដៅធ្វើឲ្យប្រសើរឡើងលើលទ្ធផលសិក្សា។ កត្តាសំខាន់ត្រូវធ្វើគឺចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល និងយកខ្លឹមសារដែលទទួលបានទៅប្រើប្រាស់នៅក្នុងការបង្រៀន ដើម្បីឆ្លុះបញ្ចាំងពីចំណេះដឹង និងជំនាញ ហើយអាចជួយឱ្យការបង្រៀនកាន់តែប្រសើរ និងកាន់តែឆ្លើយតបចំពោះតម្រូវការរបស់សិស្ស។ ការអនុវត្តបែបនេះក៏ត្រូវធ្វើឡើងសម្រាប់នាយកសាលា និងអ្នកឯកទេសអប់រំផងដែរ។ CPD សំដៅលើការអភិវឌ្ឍខ្លួនឯង និងតម្រូវឱ្យគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំប្រើប្រាស់ឱកាសដែលផ្តល់ឱ្យពួកគេដើម្បីអភិវឌ្ឍជំនាញ និងចំណេះដឹងវិជ្ជាជីវៈ។ ការអនុវត្ត CPD មានសកម្មភាពជាច្រើនដើម្បីឆ្លើយតបទៅនឹងតម្រូវការគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ។ អ្នកអនុវត្ត CPD ត្រូវចូលរួមវាយតម្លៃលើតម្រូវការ និងរៀបចំផែនការអនុវត្ត CPD រៀងៗខ្លួន ដោយផ្អែកទៅតាមតម្រូវការ បុគ្គល និងអង្គភាពហើយមានការគាំទ្រពីគណៈគ្រប់គ្រង។

### ២.១ ការរៀបចំផែនការសិក្សាវិជ្ជាជីវៈ

គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំម្នាក់ៗគួរមានផែនការសិក្សាវិជ្ជាជីវៈ។ នៅក្នុងបរិបទដទៃទៀត គេហៅផែនការសិក្សាវិជ្ជាជីវៈ ថាជាផែនការអភិវឌ្ឍន៍វិជ្ជាជីវៈ។ នៅក្នុងផែនការនេះត្រូវកំណត់ចំណុចដូចតទៅ៖

- ផ្នែកអនុវត្ត ឬចំណេះដឹងដែលត្រូវផ្តោតការយកចិត្តទុកដាក់ (នេះអាចតម្រូវឱ្យមានការវាយតម្លៃលើតម្រូវការ CPD)
- គោលបំណង
- ជំនាញសំខាន់ៗដែលចាំបាច់ដើម្បីសម្រេចគោលបំណងនីមួយៗ

- សកម្មភាព ឬវិធីសម្រេចគោលបំណង
- លក្ខណៈវិនិច្ឆ័យដែលកំណត់ពីភាពជោគជ័យ
- ពេលវេលាធ្វើការវាយតម្លៃលើវឌ្ឍនភាពដែលសម្រេចបាន និងការបញ្ចប់សកម្មភាព។

ផែនការសិក្សាវិជ្ជាជីវៈ គឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំរបស់គ្រូបង្រៀន នាយកសាលា ឬអ្នក ឯកទេសអប់រំ។ ក្នុងកិច្ចប្រជុំវាយតម្លៃប្រចាំឆ្នាំ គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំ និងអ្នកគ្រប់គ្រង ធ្វើការពិភាក្សា និងឯកភាពគ្នាលើប្រធានបទមួយ ពីរ ឬច្រើនបំផុតបី ដើម្បីបញ្ចូលក្នុងផែនការសិក្សាវិជ្ជាជីវៈ។ ប្រធានបទទាំងនេះរួមមាន៖

- តម្រូវការអភិវឌ្ឍន៍វិជ្ជាជីវៈផ្ទាល់ខ្លួន
- ចំណាប់អារម្មណ៍ដែលចង់ធ្វើការអភិវឌ្ឍ
- សកម្មភាពចាំបាច់ត្រូវអភិវឌ្ឍ (សង្កេតការបង្រៀន ឬពេលចុះពិនិត្យតាមដាន)
- វិធី ឬទ្រឹស្តីនៃការធ្វើផែនការកែលម្អសាលារៀន។

សម្រាប់ប្រធានបទនីមួយៗពាក់ព័ន្ធនឹងការអនុវត្តការងារ អាចមានការអនុវត្តសកម្មភាព CPD ច្រើនយ៉ាង។ គ្រូបង្រៀន នាយកសាលា និងអ្នកគ្រប់គ្រង ត្រូវកំណត់គោលដៅនិងលទ្ធផលរំពឹងទុកដោយមានការឯកភាពគ្នាលើសកម្មភាពអនុវត្ត និងធនធានដែលចាំបាច់។ សកម្មភាពទាំងនេះអាចមានដូចជា ការចុះឈ្មោះចូលរួមនៅក្នុងសកម្មភាព CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ណាមួយ ចេញពីបញ្ជីដែលផ្សព្វផ្សាយដោយ CPDMO។

អ្នកធ្វើផែនការ ត្រូវមានការឯកភាពគ្នាលើលក្ខណៈវិនិច្ឆ័យជោគជ័យ ថាតើភាពជោគជ័យមានលក្ខណៈដូចម្តេច ហើយធ្វើដូចម្តេចឲ្យដឹងថា បានសម្រេចគោលដៅតាមផែនការ ព្រមទាំងកំណត់ពេលជាក់លាក់ណាមួយសម្រាប់កំណត់វឌ្ឍនភាពដែលសម្រេចបាន។ ជាធម្មតាការវាយតម្លៃនេះ ត្រូវធ្វើឡើងនៅពាក់កណ្តាលអាណត្តិ និងត្រូវមានកិច្ចប្រជុំវាយតម្លៃប្រចាំឆ្នាំតាមអង្គភាព ឬគ្រឹះស្ថានសិក្សានៅចុងឆ្នាំសិក្សា ដែលជាពេលវាយតម្លៃជាផ្លូវការលើវឌ្ឍនភាពដែលគ្រូសម្រេចបាន។ សូមមើលទម្រង់គំរូផែនការសិក្សាវិជ្ជាជីវៈ និងឧទាហរណ៍នៅក្នុងឧបសម្ព័ន្ធទី ៤។

## ២.២. ប្រព័ន្ធក្រេឌីត CPD

ការផ្តល់ក្រេឌីត CPD ត្រូវកំណត់តាម៖

- ចំនួនម៉ោងនៃសកម្មភាព CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ឬក៏ចូលរួមដោយខ្លួនឯងដោយជោគជ័យ

- ចំនួនម៉ោងស្វ័យសិក្សា ដែលមានទំនាក់ទំនងជាមួយនឹងចំនួនម៉ោង CPD មានរចនាសម្ព័ន្ធច្បាស់លាស់ ឬក៏ចូលរួមដោយខ្លួនឯង
- គុណភាព ខ្លឹមសារនៃកម្មវិធី សកម្មភាព CPD និងសមត្ថភាពដែលត្រូវបានលើកកម្ពស់ (ផ្អែកលើស្តង់ដាវិជ្ជាជីវៈ)
- ការវាយតម្លៃ (ការបង្ហាញពីលទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយ)

សម្រាប់ព័ត៌មានលម្អិតអំពីប្រព័ន្ធក្រេឌីត CPD សូមមើលឯកសារស្តីពីប្រព័ន្ធសម្រាប់ផ្តល់និងរក្សាទុកក្រេឌីត CPD (២០២០-២០២១)។

## ការទទួលបានក្រេឌីត និងម៉ោងអនុវត្ត CPD

CPD គឺជាដំណើរការមួយដ៏សកម្ម ពោលគឺអ្នកចូលរួមអនុវត្តត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចសំខាន់ៗនៃខ្លឹមសារដែលត្រូវយកទៅអនុវត្តក្នុងការបង្រៀននិងរៀន សំដៅធ្វើឲ្យប្រសើរឡើងលើលទ្ធផលសិក្សា។ ចំនួនម៉ោង CPD តែមួយមុខ គឺមិនអាចចាត់ទុកថាជាមូលដ្ឋានសមស្របសម្រាប់ផ្តល់ក្រេឌីត CPD ឡើយ។ ដើម្បីទទួលបានក្រេឌីត CPD សកម្មភាព CPD នានា ចាំបាច់ត្រូវបំពេញទៅតាមស្តង់ដា (ស្តង់ដាអប្បបរមា) ខាងគុណភាព និងខ្លឹមសារ។ គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ចាំបាច់ត្រូវបង្ហាញពីលទ្ធផលរំពឹងទុក (គុណផលសិក្សា) និងលទ្ធផលចុងក្រោយ (ការផ្លាស់ប្តូរជាវិជ្ជមាន) តាមរយៈកិច្ចការវាយតម្លៃរបស់ខ្លួន។ លទ្ធផលនៃការចូលរួមអនុវត្ត CPD ត្រូវតែជាលទ្ធផលដែលអាចវាស់វែងបាន និងមានគុណភាពគ្រប់គ្រាន់ ទើបអាចទទួលបានក្រេឌីត។

គោលការណ៍មូលដ្ឋាននៃការផ្តល់ក្រេឌីត CPD ចំនួន ១ ក្រេឌីត តម្រូវឱ្យមានជាតុចូល ឬការចូលរួមសិក្សា បណ្តុះបណ្តាលផ្ទាល់ចំនួន ១៥ម៉ោង និងស្វ័យសិក្សា ៣០ ម៉ោង ឬ៤៥ម៉ោង សម្រាប់ការងារពិសោធន៍ ឬការងារចុះកម្មសិក្សា បូកជាមួយនឹងការសម្រេចបាននូវលទ្ធផលរំពឹងទុក ឬលទ្ធផលចុងក្រោយដែលអាចវាស់វែងបាន។

ក្នុងករណីអនុវត្ត CPD ដោយចូលរួមដោយខ្លួនឯង គឺមិនគិតចំនួនម៉ោងរៀនផ្ទាល់ទេ ពោលគឺគិតទៅលើគុណភាព "ជាតុចូល (input)" ដូចជា MOOC ឯកសារស្រាវជ្រាវវិជ្ជាជីវៈ ឬសៀវភៅសិក្សាជាដើម។ ដូច្នេះ សម្រាប់ CPD ដែលចូលរួមដោយខ្លួនឯង ក៏មានការអនុវត្តគោលការណ៍ស្រដៀងគ្នានឹងគោលការណ៍ខាងលើដែរ ដោយសកម្មភាព CPD ដែលមានជាតុចូល ១៥ ម៉ោង បានពីប្រភពដែលមានគុណភាពសមស្រប បូកនឹងស្វ័យសិក្សា ឬការអនុវត្តដោយខ្លួនឯង ការស្រាវជ្រាវ ឬការយកជាតុចូលទៅប្រើប្រាស់ក្នុងការអនុវត្តការងាររយៈពេល ៣០ ម៉ោង ស្របតាមស្តង់ដាអប្បបរមាខាងគុណភាព និងការសម្រេចលទ្ធផលរំពឹងទុក ឬលទ្ធផលចុងក្រោយ នឹងទទួលបានក្រេឌីតចំនួន ០១។

**មួយក្រេឌីត CPD នឹងត្រូវផ្ដល់សម្រាប់៖**

- **ការសិក្សា ឬសកម្មភាពជួបមុខផ្ទាល់រយៈពេល ១៥ ម៉ោង + ស្វ័យសិក្សា ឬការងារអនុវត្តដោយខ្លួនឯង ការស្រាវជ្រាវ ឬការយកជាតុចូលទៅប្រើប្រាស់ក្នុងការអនុវត្តការងារ រយៈពេល ៣០ ម៉ោង ឬការងារនៅក្នុងមន្ទីរពិសោធន៍ ឬការងារចុះកម្មសិក្សា ៤៥ ម៉ោង ឬ**
- **ជាតុចូលដែលបានពីប្រភពដែលមានគុណភាពសមស្រប ១៥ ម៉ោង + ស្វ័យសិក្សា ឬការអនុវត្តដោយខ្លួនឯង ការស្រាវជ្រាវ ឬការយកជាតុចូលទៅប្រើប្រាស់ក្នុងការអនុវត្តការងារ រយៈពេល ៣០ ម៉ោង ឬការងារមន្ទីរពិសោធន៍ ឬការងារចុះកម្មសិក្សា ៤៥ ម៉ោង**

**ដោយការងារទាំងអស់ខាងលើត្រូវស្របតាមស្តង់ដាគុណភាពអប្បបរមា និងការសម្រេចបានលទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយដែលនាំឱ្យមានការផ្លាស់ប្ដូរវិជ្ជមានក្នុងការអនុវត្តការងារ។**

កិច្ចប្រជុំបច្ចេកទេសដែលពាក់ព័ន្ធនឹងការងារ មិនត្រូវចាត់ទុកជា CPD ឡើយ ហើយអ្នកចូលរួមនៅក្នុងកិច្ចប្រជុំបច្ចេកទេស ក៏ពុំអាចទទួលបានក្រេឌីត CPD នោះដែរ។ ប្រព័ន្ធក្រេឌីត CPD ត្រូវបានរៀបចំឡើងប្រកបដោយសង្គតភាពជាមួយប្រព័ន្ធក្រេឌីត កម្មវិធីអប់រំគ្រូបង្រៀនដំបូង មុនពេលចេញបម្រើការងារ។[5]

## ការផ្ដល់ក្រេឌីតដល់ CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់

នៅពេល CPD មានរចនាសម្ព័ន្ធច្បាស់លាស់ត្រូវបានអនុវត្ត តាមរយៈអ្នកផ្ដល់សេវា CPD ដែលត្រូវបានទទួលស្គាល់គុណភាព ដូចជា គ្រឹះស្ថានអប់រំគ្រូ អ្នកផ្ដល់សេវាត្រូវផ្ដល់ឱ្យអ្នកពាក់ព័ន្ធទទួលខុសត្រូវគ្រប់លំដាប់ថ្នាក់នូវព័ត៌មានការអនុវត្ត CPD ដើម្បីបញ្ចូលក្នុង HRMIS បញ្ជីឈ្មោះគ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំ ដែលបានអនុវត្តសកម្មភាព CPD ណាមួយ ដោយជោគជ័យ ដូចជា កាលបរិច្ឆេទ ទីកន្លែង ពិន្ទុ/ក្រេឌីត ដែលទទួលបានជាដើម។ល។ អង្គភាពពាក់ព័ន្ធដែលទទួលខុសត្រូវលើការបញ្ចូលទិន្នន័យទៅក្នុង HRMIS អាចជាសាលារៀន ឬជាគ្រឹះស្ថានអប់រំគ្រូខ្លួនឯង, ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ, មន្ទីរ អ.យ.ក រាជធានីខេត្ត ឬការិយាល័យគ្រប់គ្រង CPD អាស្រ័យទៅតាមទីតាំង និងលទ្ធភាពមានអ៊ីនធឺណិតប្រើប្រាស់របស់សាលារៀន។ ការបញ្ចូលព័ត៌មានត្រូវធ្វើឡើងនៅកម្រិតថ្នាក់ក្រោមជាតិទាបបំផុត ដែលអាចធ្វើទៅបាន ពោលគឺនៅកម្រិតសាលារៀន ឬកម្រិតគ្រឹះស្ថានអប់រំគ្រូ។ ព័ត៌មាននេះត្រូវបានប្រមូលបញ្ចូលទៅក្នុង HRMIS ដោយប្រើប្រាស់ទម្រង់សមស្រប។ HRMIS មានផ្ទុកព័ត៌មានរួចទៅហើយអំពីអ្នកផ្ដល់សេវា CPD និង

[5] ដើម្បីទទួលបានបរិញ្ញាបត្រអប់រំ គរុសិស្សចាំបាច់ត្រូវសន្សំឱ្យបានតិចបំផុត ១២០ ក្រេឌីត។ ជាធម្មតា ពួកគេត្រូវសម្រេចឱ្យបាន ១៥ ក្រេឌីតក្នុងមួយឆមាសក្នុងរយៈពេល ៤ ឆ្នាំ។ វគ្គបណ្ដុះបណ្ដាលដែលមាន ៣ ក្រេឌីត តម្រូវឱ្យគរុសិស្សចូលរួមស្ដាប់បាឋកថារយៈពេល ៣ ម៉ោង និងធ្វើស្វ័យសិក្សា ៦ ម៉ោង (ឬធ្វើការងារក្នុងមន្ទីរពិសោធន៍ ឬការងារចុះកម្មសិក្សា ៩ ម៉ោង) ជារៀងរាល់សប្ដាហ៍ យ៉ាងហោចណាស់សម្រាប់រយៈពេល ១៥ សប្ដាហ៍ និងត្រូវបង្ហាញថាពួកគេពិតជាអាចបំពេញទៅតាមលក្ខខណ្ឌវាយតម្លៃអប្បបរមា។ ដើម្បីបាន ៣ ក្រេឌីត ជាធម្មតា គរុសិស្សចាំបាច់ត្រូវសិក្សារយៈពេល ១៣៥ ម៉ោង (ចូលរួមដាក់ស្ដែង ៤៥ ម៉ោង និងស្វ័យសិក្សា ៩០ ម៉ោង)។

សេវា CPD ដែលត្រូវបានទទួលស្គាល់គុណភាព ហើយដែលត្រូវបានវាយតម្លៃថាអាចបំពេញទៅតាមស្តង់ដាគោល និងលក្ខខណ្ឌនានាបាន (ផ្នែកទី ៤ ស្តីពីការទទួលស្គាល់គុណភាព អ្នកផ្តល់សេវា CPD និងសេវា CPD)។ ព័ត៌មាននេះនឹងត្រូវបានបង្ហាញក្នុងទម្រង់ drop-down ក្នុង HRMIS។ នៅពេលដែលឈ្មោះគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ដែលបានចូលរួមប្រកបដោយជោគជ័យនៅក្នុងសកម្មភាព CPD មានរចនាសម្ព័ន្ធច្បាស់លាស់ ត្រូវបានបញ្ចូលទៅក្នុង HRMIS ហើយព័ត៌មាននេះត្រូវបានបញ្ជាក់ផ្ទៀងផ្ទាត់នៅតាមលំដាប់ថ្នាក់ដែលពាក់ព័ន្ធ រួចក្រេឌីត CPD នឹងបង្ហាញក្នុងកម្រងព័ត៌មានរបស់គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំម្នាក់ៗក្នុង HRMIS (កំណត់ត្រាអាជីព Career Passport)។ ករណីដែលព័ត៌មានក្រេឌីត CPD ត្រូវបានបញ្ចូលទៅក្នុង HRMIS នៅកម្រិតសាលារៀន ឬគ្រឹះស្ថានអប់រំគ្រូ ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ និងមន្ទីរ អ.យ.ក រាជធានីខេត្ត ត្រូវផ្តល់ការជានាគុណភាពលើទិន្នន័យដែលត្រូវបានបញ្ចូល។ អង្គភាពទាំងនេះត្រូវធ្វើការបញ្ជាក់ផ្ទៀងផ្ទាត់ទិន្នន័យ និងធ្វើការត្រួតពិនិត្យឲ្យបានត្រឹមត្រូវលើឯកសារនានាដើម្បីបញ្ជាក់សុពលភាពព័ត៌មានដែលបញ្ចូលទៅក្នុងប្រព័ន្ធ។

បន្ទាប់ពីបានពិនិត្យបញ្ចប់ទិន្នន័យគ្រប់ផ្នែកទាំងអស់នៃសេវា CPD រួចមក រាប់បញ្ចូលទាំងការវាយតម្លៃ សៀវភៅកត់ត្រា CPD ឬកំណត់ត្រាអាជីព Career Passport ក្នុងទម្រង់រូបវន្តរបស់គ្រូបង្រៀន ឬនាយកសាលា នឹងត្រូវធ្វើបច្ចុប្បន្នភាព ដើម្បីបង្ហាញព័ត៌មាននេះ ដោយមានការបោះត្រាពីការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ, មន្ទីរ អ.យ.ក រាជធានីខេត្ត ឬការិយាល័យគ្រប់គ្រង CPD។ បុគ្គលម្នាក់ៗត្រូវរក្សាទុកកំណត់ត្រាអាជីព Career Passport ផ្ទាល់ខ្លួនដោយខ្លួនឯង (សូមមើលឧបសម្ព័ន្ធទី ៥ សម្រាប់ឧទាហរណ៍ស្តីពីសៀវភៅកត់ត្រា CPD ឬកំណត់ត្រាអាជីព Career Passport)។

## ការផ្តល់ក្រេឌីតដល់ CPD ដែលចូលរួមដោយខ្លួនឯង

នៅពេលដែលសកម្មភាព CPD ចូលរួមដោយខ្លួនឯង ត្រូវបានធ្វើឡើង នៅកម្រិតសាលារៀន កម្រង ឬសហគមន៍សិក្សាវិជ្ជាជីវៈ គ្រូបង្រៀនត្រូវយល់ស្របលើផែនការសិក្សាវិជ្ជាជីវៈជាមួយនឹងអ្នកគ្រប់គ្រងផ្ទាល់របស់ពួកគេ។ ផែនការនេះត្រូវបានរៀបចំឡើង ដើម្បីបញ្ចូលចំនួនម៉ោងជាតុចូលដែលបានពីប្រភព CPD ចូលរួមដោយខ្លួនឯង ដែលត្រូវបានទទួលស្គាល់គុណភាព ដូចជា៖ វគ្គបណ្តុះបណ្តាល MOOC អត្ថបទដកស្រង់ចេញពីឯកសារស្រាវជ្រាវដែលត្រូវបានកំណត់ឱ្យអាន ជំពូកសៀវភៅដែលត្រូវបានកំណត់ឱ្យអាន។ល។ និងផែនការដែលកំណត់ពីស្វ័យសិក្សា ឬការអនុវត្តឆ្លុះបញ្ចាំងក្នុងចំនួនណាមួយ បន្ទាប់មកគឺការរៀបចំលទ្ធផលដើម្បីបង្ហាញពីផលជះនៃសកម្មភាព CPD ដែលចូលរួមដោយខ្លួនឯង។ នៅក្នុងអំឡុងពេលវាយតម្លៃប្រចាំឆ្នាំតាមអង្គភាព ឬគ្រឹះស្ថានសិក្សា គ្រូបង្រៀន ឬនាយកសាលាបង្ហាញពីកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន ដែលជាភស្តុតាងបង្ហាញថាពួកគេពិតជាបានសម្រេចតាមផែនការសិក្សាវិជ្ជាជីវៈប្រកបដោយជោគជ័យ រួមនឹងភស្តុតាងដែលបង្ហាញពីផលជះផង (លទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយ)។ ប្រសិនបើការវាយតម្លៃនេះទទួល

បានលទ្ធផលវិជ្ជមាន អ្នកវាយតម្លៃត្រូវធ្វើការបញ្ជាក់ពីចំនួនក្រេឌីត CPD ដែលបានទទួល និងផ្សព្វផ្សាយព័ត៌មាននេះទៅកាន់ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ, មន្ទីរ អ.យ.ក រាជធានីខេត្ត ឬការិយាល័យគ្រប់គ្រង CPD ដែលត្រូវប្រមូលព័ត៌មាននេះទុកក្នុង HRMIS។ នៅក្នុងថ្ងៃអនាគត HRMIS នឹងមានបញ្ចូលព័ត៌មានអំពីប្រភព CPD ចូលរួមដោយខ្លួនឯង ដែលទទួលបានការទទួលស្គាល់គុណភាព (និងប្រភពដែលពុំទាន់ទទួលបានការទទួលគុណភាព ដែលត្រូវធ្វើការវាយតម្លៃទទួលស្គាល់គុណភាពទៅតាមករណីជាក់ស្តែង)។ ក្រោយពេលដែលព័ត៌មាននេះត្រូវបានបញ្ជាក់ផ្ទៀងផ្ទាត់នៅកម្រិតដែលពាក់ព័ន្ធរួច ក្រេឌីត CPD នឹងបង្ហាញនៅក្នុងកម្រងព័ត៌មានរបស់គ្រូបង្រៀនម្នាក់ៗ (សៀវភៅកត់ត្រា CPD ឬកំណត់ត្រាអាជីព Career Passport)។

បន្ទាប់ពីឆ្លងកាត់ការវាយតម្លៃប្រកបដោយជោគជ័យរួចមក កំណត់ត្រាអាជីព Career Passport របស់បុគ្គលិកអប់រំម្នាក់ៗ នឹងត្រូវធ្វើបច្ចុប្បន្នភាព ដើម្បីបង្ហាញព័ត៌មាននេះដោយមានការចុះហត្ថលេខា និងបោះត្រាពីអង្គភាពផ្ទាល់ ។ បុគ្គលិកអប់រំម្នាក់ៗត្រូវរក្សាសៀវភៅកត់ត្រាអាជីព និង CPD ដោយខ្លួនឯង។

ការិយាល័យគ្រប់គ្រង CPD ជាអង្គភាពថែរក្សាម៉ូឌុល CPD នៅក្នុង HRMIS និងជានាឲ្យអ្នកអនុវត្ត CPD មានលទ្ធភាពចូលមើលទិន្នន័យរបស់ខ្លួននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដូចពន្យល់ពីខាងដើម ការកត់ត្រាក្រេឌីត CPD ទៅក្នុង HRMIS ត្រូវធ្វើឡើងនៅកម្រិតថ្នាក់ក្រោមជាតិទាបបំផុតដែលអាចធ្វើទៅបាន (សាលារៀន ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ, មន្ទីរ អ.យ.ក រាជធានីខេត្ត ឬការិយាល័យគ្រប់គ្រង CPD)។ មានច្រកចំនួនពីរដើម្បីធ្វើការកត់ត្រាទិន្នន័យ CPD ទៅក្នុង HRMIS៖

i) **អ្នកផ្តល់សេវា** : អ្នកផ្តល់សេវា CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ និងមានការទទួលស្គាល់គុណភាព ត្រូវកត់ត្រាក្រេឌីតរបស់អ្នកចូលរួមសកម្មភាព CPD និងបញ្ចូនបញ្ជីសកម្មភាព CPD និងលទ្ធផល/ពិន្ទុ ទៅក្នុង HRMIS (នេះគឺជាច្រកសម្រាប់ធ្វើការកត់ត្រាក្រេឌីត CPD ដែលអ្នកចូលរួមបានទទួល តាមរយៈការចូលរួមនៅក្នុងសកម្មភាព CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់)។

ii) **សាលារៀន:** សាលារៀនសាមី (ឬ ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ / មន្ទីរ អ.យ.ក រាជធានីខេត្ត, នៅក្នុងករណីដែលសាលារៀនពុំមានអ៊ីនធឺណែតប្រើប្រាស់) វាយតម្លៃតាមអង្គភាព ឬគ្រឹះស្ថានសិក្សាប្រចាំឆ្នាំ លើការបញ្ចប់សកម្មភាព CPD ប្រកបដោយជោគជ័យ ធៀបនឹងផែនការសិក្សាវិជ្ជាជីវៈរបស់បុគ្គលិកអប់រំណាម្នាក់ដោយធ្វើការវាយតម្លៃលើភស្តុតាង ដែលត្រូវបានបង្ហាញនៅក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ពួកគេ (នេះគឺជាច្រកសម្រាប់កត់ត្រាក្រេឌីត CPD ដែលទទួលបានពីការចូលរួមក្នុងស្វ័យ CPD ឬCPD ដែលចូលរួមដោយខ្លួនឯង។

ការិយាល័យគ្រប់គ្រង CPD ដែលឋិតនៅក្នុងនាយកដ្ឋានបុគ្គលិក នឹងចេញវិញ្ញាបនបត្រ CPD រៀង

រាល់ ៥ ឆ្នាំម្តង[6] (ឬទៅតាមការចាំបាច់សម្រាប់ការឡើងឋានៈវិជ្ជាជីវៈ) ដែលមានបង្ហាញពីចំនួនក្រេឌីត CPD ដែលបុគ្គលិកអប់រំបានទទួល។ អ្នកផ្តល់សេវា CPD ដែលត្រូវបានទទួលស្គាល់គុណភាព រាប់បញ្ចូលទាំងដៃគូរអភិវឌ្ឍន៍អនុវត្តគម្រោងផងដែរ អាចប្រើប្រាស់ ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃ CPD ដោយខ្លួនឯង ដូចជា កត់ត្រាវត្តមាន ការចូលរួម និងលទ្ធផលរបាយការណ៍ស្តីពីសកម្មភាព CPD/វិក្រឹតការ/ ការបណ្តុះបណ្តាល ។ល។ រួចបំប្លែងជាក្រេឌីត CPD ដើម្បីបញ្ចូលទៅក្នុងម៉ូឌុល CPD នៃ HRMIS ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលមានចែងនៅផ្នែកទី ២ ខាងលើ។ ការផ្តល់ក្រេឌីត CPD ត្រូវធ្វើឡើងដោយការិយាល័យគ្រប់គ្រង CPD ដែលជាអង្គភាពផ្តល់ការទទួលស្គាល់ គុណភាពសេវា CPD និងផ្តល់ក្រេឌីតដល់សេវា CPD ផ្អែកតាមប្រព័ន្ធផ្តល់និងរក្សាទុកក្រេឌីត CPD។ កំណត់ត្រាអាជីព Career Passport ដែលរក្សាទុកដោយគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំម្នាក់ៗ នឹងត្រូវយកមកប្រើប្រាស់នៅក្នុងគ្រប់ករណីទាំងអស់ ដើម្បីកត់ត្រាសកម្មភាព CPD និងក្រេឌីតដែលទទួលបាន។ ព័ត៌មានទាំងនេះក៏នឹងត្រូវកត់ត្រាទៅក្នុងម៉ូឌុល CPD នៃ HRMIS ផងដែរ។

ប្រព័ន្ធផ្តល់និងរក្សាទុកក្រេឌីត CPD នឹងត្រូវអនុវត្តជាដំណាក់ៗ ចាប់ផ្តើមជាមួយនឹងក្រេឌីតដែលទទួលបានពី CPD ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ ចាប់ពីឆ្នាំ ២០២១ ទៅ។ ការអនុវត្តសកម្មភាព CPD នឹងពង្រីកវិសាលភាពបន្ថែមទៀត ដើម្បីបញ្ចូលលទ្ធផល CPD ដែលចូលរួមដោយខ្លួនឯងនៅឆ្នាំ ២០២៥។ ដំបូងនឹងមានការផ្តល់ក្រេឌីត CPD ដល់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ដែលចូលរួមនៅក្នុងសកម្មភាព CPD មួយចំនួនដែលត្រូវបានផ្តល់ដោយអ្នកផ្តល់សេវា CPD មានការទទួលស្គាល់គុណភាព ដូចជា គ្រឹះស្ថានអប់រំគ្រូ ដែលកំពុងអនុវត្តកម្មវិធី TQU នាពេលបច្ចុប្បន្ន (ដូចជាវិទ្យាស្ថានគរុកោសល្យភ្នំពេញ) និងគម្រោងរបស់ដៃគូអភិវឌ្ឍន៍ ដែលផ្តល់វគ្គបណ្តុះបណ្តាលវិក្រឹតការ ដូចជា គម្រោង STEPCam, SEIP SBM និង USESDP-2 ជាដើម។ CPDMO នឹងមានការពិចារណាក្នុងការផ្តល់ក្រេឌីតទៅលើសកម្មភាព CPD ដែលបាននិងកំពុងធ្វើនាពេលបច្ចុប្បន្ននេះផ្អែកលើភស្តុតាងជាក់ស្តែងតាមករណីដែលអាចធ្វើទៅបាន។

## ២.៣ ទំនាក់ទំនងនិងការបន្សីុទ្ធរវាងប្រព័ន្ធ CPD និងប្រព័ន្ធផ្សេងទៀត

ប្រព័ន្ធ CPD មានទំនាក់ទំនងជាមួយនឹងប្រព័ន្ធផ្សេងទៀត ដូចជា ប្រព័ន្ធវាយតម្លៃកម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សា ប្រព័ន្ធវាយតម្លៃគន្លងអាជីពគ្រូបង្រៀន ប្រព័ន្ធអប់រំគ្រូដំបូង និងប្រព័ន្ធលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនជាដើម។

[6] នេះអាចប្តូរទៅជារៀងរាល់មួយឆ្នាំម្តងវិញ។

## CPD និងប្រព័ន្ធវាយតម្លៃ

ក្របខណ្ឌអនុវត្តគន្លងអាជីពគ្រូបង្រៀនជាផ្នែកមួយនៃរបៀបវារៈអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។ ការវាយតម្លៃគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ មានពីរទម្រង់គឺ ការវាយតម្លៃកម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សា និងការវាយតម្លៃគន្លងអាជីពគ្រូបង្រៀន (ក្របខណ្ឌ និងសៀវភៅណែនាំប្រតិបត្តិគន្លងអាជីពគ្រូបង្រៀន TCP ២០២១)។ គ្រូ និងនាយកសាលាទាំងអស់ ត្រូវឆ្លងកាត់ការវាយតម្លៃកម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សា ដើម្បីកំណត់ និងផ្តល់រង្វាន់ដល់អ្នកដែលធ្វើបានល្អ នៅក្នុងការងារដឹកនាំក៏ដូចជាការងារបង្រៀន ការចូលជាសមាជិកក្នុងក្រុមបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាដើម។ ការវាយតម្លៃទាំងនេះត្រូវរកឲ្យឃើញ និងទទួលស្គាល់នូវចំណុចខ្វះខាតដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលការងារ។ ការវាយតម្លៃផ្តោតលើសមត្ថភាពវិជ្ជាជីវៈ ដូចដែលបានកំណត់នៅក្នុងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ដើម្បីសម្រេចឲ្យបានគោលដៅ CPD។ អ្នកដែលទទួលបានលទ្ធផលល្អ ហើយមានបំណងចង់ឡើងឋានៈវិជ្ជាជីវៈទៅកម្រិតខ្ពស់បន្ទាប់ក្នុងគន្លងអាជីពគ្រូបង្រៀន អាចស្នើសុំឱ្យមានការវាយតម្លៃឡើងឋានៈវិជ្ជាជីវៈជាផ្លូវការ។ ការវាយគន្លងអាជីពគ្រូបង្រៀនផ្តោតលើលក្ខណៈវិនិច្ឆ័យចំនួន៥ សម្រាប់គ្រូបង្រៀន និងនាយកសាលា៖ គុណវុឌ្ឍិ បទពិសោធការងារ ស្នាដៃការងារ លទ្ធផលសិក្សារបស់សិស្ស និងសមត្ថភាពវិជ្ជាជីវៈដែលបានកំណត់ក្នុងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន និងលក្ខណៈវិនិច្ឆ័យចំនួន៤ សម្រាប់អ្នកឯកទេសអប់រំ៖ គុណវុឌ្ឍិ បទពិសោធការងារ ស្នាដៃការងារ និងសមត្ថភាពវិជ្ជាជីវៈ។ អ្នកដែលទទួលជោគជ័យពីការវាយតម្លៃកម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សា គួរទទួលបានការលើកទឹកចិត្ត និងលាភការផ្សេងៗ។ ការវាយតម្លៃគន្លងអាជីព ត្រូវផ្តល់ឋានៈវិជ្ជាជីវៈជាក់លាក់ណាមួយនៅក្នុងគន្លងទាំងបី ដោយមានការឡើងប្រាក់បំណាច់ឋានៈវិជ្ជាជីវៈដែលបានកំណត់។

ដូច្នេះ ក្រេឌីត CPD រួមចំណែកដល់លទ្ធផលនៃការវាយតម្លៃកម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សាផង និងលទ្ធផលនៃការវាយតម្លៃគន្លងអាជីពគ្រូបង្រៀនផង (សូមមើលរូបភាពទី ១ ខាងក្រោម)។ ឯកសារ *ក្របខណ្ឌ និងសៀវភៅណែនាំប្រតិបត្តិគន្លងអាជីពគ្រូបង្រៀន TCP ឆ្នាំ២០២១* ផ្តល់ការពន្យល់លម្អិតអំពីប្រព័ន្ធវាយតម្លៃ និងរបៀបដាក់ពិន្ទុលើលក្ខណៈវិនិច្ឆ័យនីមួយៗដែលត្រូវប្រើប្រាស់នៅក្នុងការវាយតម្លៃកម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សា និងគន្លងអាជីពគ្រូបង្រៀន។

## CPD និងប្រព័ន្ធគន្លងអាជីពគ្រូបង្រៀន

*រូបភាពទី ១៖ ទំនាក់ទំនងរវាងប្រព័ន្ធ CPD, HRMIS, និង TCP*




**ក្រេឌីត CPD – ការរួមចំណែកដល់ការឡើងឋានៈវិជ្ជាជីវៈស្របតាមគន្លងអាជីពគ្រូបង្រៀន (នឹងបន្ត....)**

ប្រព័ន្ធ CPD មានទំនាក់ទំនងជាមួយនឹងគន្លងអាជីពគ្រូបង្រៀននៅច្រើនកម្រិត (សូមមើលរូបភាពទី ២ ខាងក្រោម)។

ក្រេឌីត CPD រួមចំណែកផ្ទាល់ដល់ការសម្រេចបានលក្ខណៈវិនិច្ឆ័យទី ១៖ គុណវុឌ្ឍិ ១៥% ដែលត្រូវកត់ត្រានៅក្នុងប្រព័ន្ធ HRMIS។

ក្រេឌីត CPD រួមចំណែកដោយប្រយោលការសម្រេចបានលក្ខណៈវិនិច្ឆ័យទី ៣៖ ស្នាដៃការងារ ១៨% និងត្រូវបានកត់ត្រាក្នុងប្រព័ន្ធ HRMIS តាមរយៈប្រព័ន្ធវាយតម្លៃប្រចាំឆ្នាំ។

ការអនុវត្តសកម្មភាព CPD រួមចំណែកផ្ទាល់ក្នុងការសម្រេចបានលក្ខណៈវិនិច្ឆ័យទី ៥៖ សមត្ថភាពវិជ្ជាជីវៈ (វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា)។

*រូបភាពទី ២៖ ក្របខណ្ឌវាយតម្លៃគន្លងអាជីពគ្រូបង្រៀន*

| លក្ខណៈវិនិច្ឆ័យ | ប្រភពផ្ទៀងផ្ទាត់ | ទម្ងន់ពិន្ទុ (%) |
|---|---|---|
| គុណវុឌ្ឍិ (រាប់បញ្ចូលក្រេឌីត CPD) | ប្រព័ន្ធ HRMIS | ១៥ |
| បទពិសោធការងារ | ប្រព័ន្ធ HRMIS | ១៨ |
| ស្នាដៃការងារ | ការវាយតម្លៃកម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សា | ១៨ |
| លទ្ធផលសិក្សារបស់សិស្ស | លទ្ធផលសិក្សារបស់សិស្ស | ១៤ |
| សមត្ថភាពវិជ្ជាជីវៈ (វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា) | ការវាយតម្លៃកម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សា | ៣៥ |

### ក្រេឌីត CPD និងការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (Teacher Qualification Upgrade TQU)

ប្រទេសកម្ពុជាបានប្តេជ្ញាឱ្យគ្រូបង្រៀនទាំងអស់មានគុណវុឌ្ឍិយ៉ាងហោចណាស់កម្រិតបរិញ្ញាបត្រអប់រំ (B Ed) (ឬ ១២+៤)។ បច្ចុប្បន្ននេះមានការអនុវត្តកម្មវិធីជាតិមួយ ដើម្បីជួយឱ្យគ្រូដែលបច្ចុប្បន្នមានគុណវុឌ្ឍិ ១២+២ អាចបង្កើនសមត្ថភាពរបស់ខ្លួនដល់កម្រិតបរិញ្ញាបត្រអប់រំ ដោយពួកគេត្រូវចូលរួមនៅក្នុងវគ្គដំឡើងគុណវុឌ្ឍិនៅវិទ្យាស្ថានជាតិអប់រំសម្រាប់ករណីគ្រូមធ្យមសិក្សាទុតិយភូមិ ចូលរួមនៅក្នុងវគ្គដំឡើងគុណវុឌ្ឍិនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ សម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ និងចូលរួមក្នុងវគ្គដំឡើងគុណវុឌ្ឍិនៅវិទ្យាស្ថានគរុកោសល្យភ្នំពេញ (PTEC) សម្រាប់គ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការខេត្ត។ ក្រេឌីត CPD ក៏អាចរួមចំណែកដល់ការលើកកម្ពស់គុណវុឌ្ឍិរបស់គ្រូបង្រៀនផងដែរ។ តម្លៃ ១ ក្រេឌីត ស្មើនឹងការរៀន ១ ម៉ោងក្នុងមួយសប្តាហ៍រយៈពេលមួយឆមាសដែលមានរយៈពេលយ៉ាងហោចណាស់ ១៥ សប្តាហ៍។ សម្រាប់ការរៀន ១ ម៉ោង ត្រូវមានការធ្វើស្វ័យសិក្សាយ៉ាងហោចណាស់ ២ ម៉ោង ហើយបរិមាណស្វ័យសិក្សាកើនឡើងទៅតាមកម្រិតនៃការសិក្សា។ វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់សម្រាប់បំប្លែងម៉ោងរៀនទៅជាក្រេឌីត ក៏ត្រូវបានប្រើប្រាស់នៅក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូផងដែរ។

### ក្រេឌីត CPD – ការរួមចំណែកដល់ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន

ដើម្បីបញ្ចប់កម្មវិធីអប់រំគ្រូដំបូងប្រកបដោយជោគជ័យ និងទទួលបានបរិញ្ញាបត្រអប់រំ គរុសិស្សត្រូវមាន យ៉ាងតិច ១២០ ក្រេឌីត ដោយត្រូវបែងចែកក្រេឌីតទាំងនេះទៅតាមមុខវិជ្ជាសិក្សាដូចខាងក្រោម៖

១. ការសិក្សាអំពីការអប់រំ

២. ចំណេះដឹងមុខវិជ្ជា (មត្តេយ្យសិក្សា និងបឋមសិក្សា) / ខ្លឹមសារមុខវិជ្ជាដែលសិក្សានៅតាមសាលារៀន (មធ្យមសិក្សាមបឋមភូមិ)
៣. ការសិក្សាអំពីកម្មវិធីសិក្សា (វិធីសាស្ត្របង្រៀនដែលផ្សារភ្ជាប់ជាមួយនឹងមុខវិជ្ជាដែលសិក្សានៅតាមសាលារៀន)
៤. ការបង្កើនសមត្ថភាពផ្នែកភាសា (ការសរសេរសម្រាប់គោលបំណងសិក្សា ការអាន ការធ្វើបទបង្ហាញ) ជាភាសាបរទេស (អង់គ្លេស ឬបារាំង)
៥. ការស្រាវជ្រាវអំពីការអប់រំ (ទ្រឹស្តី និងការអនុវត្តការស្រាវជ្រាវសម្រាប់ការសិក្សា)
៦. ការធ្វើកម្មសិក្សា (ការអនុវត្តការបង្រៀន)
៧. វគ្គសិក្សាដែលសំខាន់ និងចាំបាច់ (ប្រធានបទ ឬខ្លឹមសារពាក់ព័ន្ធនឹងការបង្រៀន)

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនបានកំណត់ឱ្យរៀនត្រឹម ៦០ ក្រេឌីតលើចំនួន ១២០ ក្រេឌីត ដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រអប់រំ ចំពោះអ្នកសិក្សាដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- គុណវុឌ្ឍិ ១២ + ២
- បទពិសោធន៍ធ្វើជាគ្រូរបស់ក្រសួងអប់រំ យុវជន និងកីឡា រយៈពេល ៥ ឆ្នាំ
- អាយុមិនច្រើនជាង ៥៥ ឆ្នាំនៅពេលដាក់ពាក្យសុំ
- ការប្រឡងចូលរៀនជាប់ (ប្រកាសលេខ ១៨៧០)

ដូច្នេះ កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនត្រូវការការសិក្សាពេញម៉ោង ២ ឆ្នាំ ឬការចូលរួមក្នុងវគ្គសិក្សានៅវិស្សមកាល (intensive summer courses) រយៈពេល ២ ឆ្នាំ ស្មើនឹង ៥០ ម៉ោងក្នុងមួយសប្តាហ៍ រយៈពេល ៩ សប្តាហ៍ (សរុបប្រមាណ ៩០០ ម៉ោង សម្រាប់ការរៀនជួមមុខផ្ទាល់)។

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនដែលបានចាត់ចូលក្នុងសកម្មភាព CPD បានកំណត់ត្រឹម៦០ ក្រេឌីតសម្រាប់សិក្សាដល់កម្រឹតបរិញ្ញាបត្រ ។ ប៉ុន្តែការណត់ភាគរយលើក្រេឌីត CPD សម្រាប់មុខវិជ្ជាសិក្សានីមួយៗផ្សេងៗគ្នា និងទៅតាមប្រភេទគ្រូបង្រៀន ឧទាហរណ៍ សម្រាប់គ្រូបឋមសិក្សាដែលមានសញ្ញាបត្របរិញ្ញាបត្ររងផ្នែកការបង្រៀន ឬបរិញ្ញាបត្រអប់រំបឋមសិក្សា ការចូលរួមនៅក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូអាចឱ្យពួកគេទទួលបាន ២ ឬ ៣ ក្រេឌីតក្នុងចំណោម ៦ ក្រេឌីត។ការទទួលបានក្រេឌីតពីCPD ដរាបណាសេវា CPD ដែលផ្តល់ឱ្យត្រូវបានទទួលស្គាល់ថាជា "ការសិក្សាអំពីការអប់រំ"។ ក្នុងតារាងទី១ខាងក្រោម មុខវិជ្ជាសិក្សានីមួយៗក្នុងចំណោមមុខវិជ្ជាសិក្សាទាំង៧ ត្រូវបានកំណត់ភាគរយនៃក្រេឌីតដែលផ្តល់ដោយ CPD ខុសៗគ្នាគឺ១០០% សម្រាប់មុខវិជ្ជាជម្រើស ១០០% សម្រាប់មុខវិជ្ជាភាសាបរទេស និងបំណិនសិក្សា ហើយចន្លោះពី ៣៣% ទៅ ៥០% សម្រាប់មុខវិជ្ជាសិក្សាផ្សេងទៀត)។ សូមមើលតារាងទី ១ ខាងក្រោមសម្រាប់ព័ត៌មានលម្អិតអំពីលក្ខខណ្ឌទៅតាមមុខវិជ្ជាសិក្សានីមួយៗ សម្រាប់គ្រូប្រភេទផ្សេងៗគ្នា។

CPD និងប្រព័ន្ធប្រឹក្សាគរុកោសល្យ (Mentoring system)

បច្ចុប្បន្ននេះ មានប្រព័ន្ធផ្តល់ប្រឹក្សាគរុកោសល្យជាច្រើនសម្រាប់គ្រូ ដែលក្នុងនោះគ្រូទទួលបានការគាំទ្រអំពីរបៀបធ្វើឱ្យការបង្រៀនក្នុងថ្នាក់កាន់តែប្រសើរ តាមរយៈការជួបពិភាក្សាជាប្រចាំជាមួយនឹងអ្នកផ្តល់ប្រឹក្សា គរុកោសល្យ។ ការទទួលបានប្រយោជន៍ពីការប្រឹក្សាគរុកោសល្យ សូម្បីតែនៅក្នុងប្រព័ន្ធផ្តល់ប្រឹក្សាគរុកោសល្យដែលត្រូវបានទទួលស្គាល់គុណភាពក៏ដោយ ត្រូវបានគេចាត់ទុកថាជា CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់។ គ្រូអាចទទួលបានក្រេឌីត CPD តាមរយៈការចូលរួមនៅក្នុងកម្មវិធីផ្តល់ប្រឹក្សាគរុកោសល្យប្រកបដោយជោគជ័យ និងបង្ហាញថាការអនុវត្តនៅក្នុងថ្នាក់រៀនរបស់ពួកគេពិតជាបានប្រសើរជាងមុន បន្ទាប់ពីបានចូលរួមនៅក្នុងកម្មវិធីផ្តល់ប្រឹក្សាគរុកោសល្យ ដោយត្រូវបង្ហាញនូវភស្តុតាងដែលអាចវាស់វែងបាន។ ការផ្តល់ក្រេឌីត CPD ត្រូវបានធ្វើឡើង ដោយប្រើប្រាស់រូបមន្តដែលកំណត់នៅក្នុងផ្នែក ២.២ ខាងលើ៖ កម្មវិធីផ្តល់ប្រឹក្សាគរុកោសល្យដែលត្រូវបានទទួលស្គាល់គុណភាពនីមួយៗ អាចឱ្យគេទទួលបានក្រេឌីត CPD ក្នុងចំនួនមួយដែលបានកំណត់។ អ្នកទទួលបានការប្រឹក្សា (គ្រូដែលទទួលបានការគាំទ្រក្នុងទម្រង់ជាការផ្តល់ប្រឹក្សាគរុកោសល្យ) និងអ្នកផ្តល់ប្រឹក្សាគរុកោសល្យ (គ្រូ/អ្នកគ្រប់គ្រងដែលផ្តល់ការប្រឹក្សាគរុកោសល្យដល់គ្រូបង្រៀន) សុទ្ធតែអាចទទួលបានក្រេឌីត CPD ទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងប្រព័ន្ធក្រេឌីត CPD។ ធាតុចូលដែលមានរចនាសម្ព័ន្ធច្បាស់លាស់ផ្តល់ដល់គ្រូបង្រៀនដែលទទួលបានការផ្តល់ប្រឹក្សាគរុកោលស្យអាចមានដូចជា៖ ការអានឯកសារយោងស្តីពីគរុកោសល្យ ការចូលរួមនៅក្នុងកិច្ចប្រជុំរបស់សហគមន៍សិក្សាវិជ្ជាជីវៈ ដោយមានការកត់ត្រាត្រឹមត្រូវ និងការប្រើប្រាស់គោលវិធីបង្រៀនថ្មីៗនៅក្នុងថ្នាក់រៀន ក្រោមការសង្កេតមើលរបស់អ្នកផ្តល់ប្រឹក្សាគរុកោសល្យដែលក្រោយមកត្រូវផ្តល់ការគាំទ្រ ដើម្បីកំណត់ពីចំណុចដែលត្រូវធ្វើការកែលម្អបន្ថែម និងយុទ្ធសាស្ត្រដែលត្រូវប្រើប្រាស់ ដើម្បីសម្រេចការកែលម្អនេះ។ បន្ទាប់មក គ្រូបង្រៀនដែលទទួលបានការផ្តល់ប្រឹក្សាគរុកោសល្យត្រូវអនុវត្តសកម្មភាពស្វ័យសិក្សា ដូចជាអានឯកសារបន្ថែមនិងត្រូវសរសេរកំណត់ត្រាឆ្លុះបញ្ចាំង/របាយការណ៍ បង្ហាញឱ្យឃើញថាតើពួកគេបានដោះស្រាយបញ្ហាទាំងនេះដោយរបៀបណា និងបង្ហាញពីអ្វីដែលពួកគេបានរៀនពីបទពិសោធនេះ។ សៀវភៅកត់ត្រាអំណានកំណត់ត្រាការផ្តល់ប្រឹក្សាគរុកោសល្យ និងរបាយការណ៍វឌ្ឍនភាព ដែលអាចបញ្ចូលទៅក្នុងកម្រងស្នាដៃវិជ្ជាជីវៈ នឹងត្រូវបញ្ជាក់ផ្ទៀងផ្ទាត់នៅពេលមានការវាយតម្លៃកម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សាបន្ទាប់ (សូមមើលឧទាហរណ៍នៅក្នុងឧបសម្ព័ន្ធទី ៣)។

អ្នកផ្តល់ប្រឹក្សាគរុកោសល្យអាចទទួលបានធាតុចូលដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ដូចជា តាមរយៈការចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលសម្រាប់អ្នកផ្តល់ប្រឹក្សាគរុកោសល្យដែលធ្វើឡើងនៅកម្រិតកម្រង ការអានឯកសារគរុកោសល្យ ការចូលរួមនៅក្នុងកិច្ចប្រជុំរបស់សហគមន៍សិក្សាវិជ្ជាជីវៈដែលមានការកត់ត្រាត្រឹមត្រូវ និង/ឬការផ្តល់ការគាំទ្រដល់អ្នកដែលត្រូវទទួលការប្រឹក្សាគរុកោសល្យ ដើម្បីជួយឱ្យពួកគេកំណត់ពីផ្នែកដែលត្រូវធ្វើការកែលម្អ និងយុទ្ធសាស្ត្រដើម្បីសម្រេចបាននូវការកែលម្អនេះ។ អ្នកផ្តល់ប្រឹក្សាគរុកោសល្យ

ក៏ចាំបាច់ត្រូវបង្ហាញឱ្យឃើញពីលទ្ធផលរំពឹងទុក (outputs) និងលទ្ធផលចុងក្រោយ (outcomes) ចេញពីការផ្តល់ប្រឹក្សាគរុកោសល្យផងដែរ ដូចជាតាមរយៈការសរសេរកំណត់ត្រាឆ្លុះបញ្ចាំង និងរបាយការណ៍បង្ហាញពីយុទ្ធសាស្រ្តត្រូវបានប្រើប្រាស់ ដើម្បីជួយឱ្យគ្រូបង្រៀនឆ្លើយតបចំពោះបញ្ហាប្រឈមដែលពួកគេជួបប្រទះនៅក្នុងការបង្រៀន និងការដាក់ចេញនូវជំហានបន្ទាប់សម្រាប់អ្នកទទួលប្រឹក្សាគរុកោសល្យផង និងអ្នកផ្តល់ប្រឹក្សាគរុកោសល្យផង។ ខណៈអ្នកផ្តល់ប្រឹក្សាគរុកោសល្យយកមេរៀនទាំងនេះទៅប្រើប្រាស់ នឹងត្រូវមានការពិនិត្យវាយតម្លៃ ដោយអ្នកផ្តល់ប្រឹក្សាគរុកោសល្យជាន់ខ្ពស់ (master mentor) ក្នុងកិច្ចប្រជុំវាយតម្លៃកម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សាប្រចាំឆ្នាំ។ រាល់សកម្មភាពទាំងអស់នឹងត្រូវធ្វើការគណនាជាចំនួនម៉ោងស្របតាមរូបមន្តដែលប្រើប្រាស់សម្រាប់ផ្តល់ក្រេឌីត CPD។

*តារាងទី ១៖ ចំនួនក្រេឌីតសម្រាប់មុខវិជ្ជាសិក្សានៅក្នុងកម្មវិធីអប់រំគ្រូដំបូង និងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនដើម្បីទទួលបានបរិញ្ញាបត្រអប់រំផ្នែកការបង្រៀន និងចំនួនក្រេឌីត CPDសម្រាប់កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្គាញនៅក្នុងវង់ក្រចក ( ប្រកាសលេខ ១៨៧០ នាយកដ្ឋានបណ្តុះបណ្តាលវិក្រឹតការ ឆ្នាំ ២០១៩ )*

| | មុខវិជ្ជាសិក្សា | គ្រូមត្តេយ្យសិក្សា (ពេញសិទ្ធិ) **គំរូ គ** | គ្រូមត្តេយ្យសិក្សាមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅក្នុងមុខវិជ្ជាពាក់ព័ន្ធ (TQU) **គំរូ ខ** | គ្រូមត្តេយ្យសិក្សាមានសញ្ញាបត្របរិញ្ញាបត្ររងសម្រាប់ការបង្រៀនឬបរិញ្ញាបត្រមិនមែនជំនាញអប់រំកុមារតូច (TQU) **គំរូ ក** | គ្រូបឋមសិក្សា **គំរូ គ** | គ្រូបឋមសិក្សាមានសញ្ញាបត្របរិញ្ញាបត្រក្នុងមុខវិជ្ជាពាក់ព័ន្ធ (TQU) **គំរូ ខ** | គ្រូបឋមសិក្សាមានសញ្ញាបត្របរិញ្ញាបត្ររងសម្រាប់ការបង្រៀនឬបរិញ្ញាបត្រមិនជំនាញអប់រំបឋមសិក្សា (TQU) **គំរូ ក** | គ្រូមធ្យមសិក្សាបឋមភូមិ **គំរូ គ** | គ្រូមធ្យមសិក្សាបឋមភូមិមានសញ្ញាបត្របរិញ្ញាបត្រត្រូវមុខវិទ្យាឯកទេស (TQU) **គំរូ ខ** | គ្រូមធ្យមសិក្សាបឋមភូមិមានសញ្ញាបត្របរិញ្ញាបត្ររងក្នុងការបង្រៀន ឬបរិញ្ញាបត្រមិនចំឯកទេសមុខវិជ្ជាដើម (TQU) **គំរូ ក** |
|---|---|---|---|---|---|---|---|---|---|---|
| ១ | ការសិក្សាអប់រំ | ១២ | ៤ (២) | ៦ (៣) | ១២ | ៤ (២) | ៦ (៣) | ១៥ | ៤ (២) | ៦ (៣) |
| ២ | មុខវិជ្ជាឯកទេស | ២៥ | ៩ (៤) | ៦ (៣) | ២៥ | ៩ (៤) | ១៤ (៥) | ៥៥ | ៩ (៤) | ២២ (៨) |
| ៣ | ការសិក្សាអំពីកម្មវិធីសិក្សា | ៥៤ | ០ (០) | ២៤ (១២) | ៥៤ | ០ (០) | ២១ (៧) | ១២ | ០ (០) | ៩ |
| ៤ | ការបង្កើនចំណេះដឹងភាសា | ២ | ០ (០) | ២ (២) | ២ | ០ (០) | ២ (២) | ៨ | ០ (០) | ៦ (៦) |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | និងជំនាញពិភាក្សាអំពីបញ្ហាដែលពាក់ព័ន្ធនឹងការសិក្សា | | | | | | | | | |
| ៥ | ការស្រាវជ្រាវអំពីការអប់រំ | ៣ | ៣ (១) | ៣ (១) | ៣ | ៣ (១) | ៣ (១) | ៣ | ៣ (១) | ៣ (១) |
| ៦ | កម្មសិក្សាគរុកោសល្យ | ២០ | ០ (០) | ០ (០) | ២០ | ០ (០) | ០ (០) | ២០ | ០ (០) | ០ (០) |
| ៧ | មុខវិជ្ជារួម (ចាំបាច់ និងសំខាន់) | ៤ | ២ (១) | ៤ (២) | ៤ | ២ (២) | ៤ (២) | ៧ | ២ (១) | ៤ (២) |
| | មុខវិជ្ជាជម្រើស | ០ | ១២ (១២) | ១៥ (១៥) | ០ | ១២ (១២) | ១០ (១០) | ០ | ១២ (១២) | ១០ (១០) |
| | សរុប | ១២០ | ៣០ (១៥) | ៦០ (៣០) | ១២០ | ៣០ (១៥) | ៦០ (៣០) | ១២០ | ៣០ (១៥) | ៦០ (៣០) |

កម្រិតអតិបរមានៃចំនួនក្រេឌីត CPD ដែលត្រូវបានលើកស្នើឡើង ត្រូវបានបង្ហាញនៅក្នុងវង់ក្រចក ផ្អែកទៅតាមរូបមន្ត ១០០% សម្រាប់មុខវិជ្ជាភាសាបរទេស និងបំណិនសិក្សា និងមុខវិជ្ជាជាជម្រើស និងចន្លោះពី ៣៣% - ៥០% សម្រាប់មុខវិជ្ជាសិក្សាដទៃទៀត។ ចំនួនក្រេឌីត CPD អតិបរមាសម្រាប់ជួយដល់ការដំឡើងគុណវុឌ្ឍិមានចំនួនសរុប ៥០%[7]។

[7] នេះគឺជាអនុសាសន៍ដែលបានពីទីប្រឹក្សាបច្ចេកទេសនៃកម្មវិធី STEPCam របស់អង្គការយូណេស្កូ។ ក្រសួងអប់រំ យុវជន និងកីឡា អាចសម្រេចចិត្តធ្វើការកែសម្រួលនាពេលក្រោយទៀត។

# ៣. គោលការណ៍ណែនាំស្តីពីការគ្រប់គ្រង

## ៣.១ កម្រិតនៃការទទួលខុសត្រូវ និងភារកិច្ច

ផ្នែកនេះបង្ហាញពីការទទួលខុសត្រូវនិងភារកិច្ចនៃកម្រិតនីមួយៗរបស់ប្រព័ន្ធ CPD ។

**សាលារៀន គណៈកម្មការ CPD កម្រងសាលារៀន និងសហគមន៍សិក្សាវិជ្ជាជីវៈ**

CPD សម្រាប់គ្រូបង្រៀន និងនាយកសាលាត្រូវគ្រោងរៀបចំ និងសម្របសម្រួលនៅកម្រិតសាលារៀន ហើយសាលារៀននីមួយៗត្រូវមានគណៈកម្មការ CPD។ គណៈកម្មការ CPD គឺជាអនុក្រុមរបស់គណៈកម្មាការគ្រប់គ្រងសាលារៀន ដែលមាននាយកសាលាធ្វើជាប្រធាន និងមានសមាសភាគប្រធានក្រុមបច្ចេកទេសដែលបំពេញតួនាទីជាអ្នកសម្របសម្រួលនិងគ្រូមានបទពិសោធម្នាក់ទៀតទទួលខុសត្រូវផ្តល់ការប្រឹក្សាគរុកោសល្យដល់គ្រូបង្រៀនដទៃទៀត។

គណៈកម្មការនេះទទួលខុសត្រូវលើការរៀបចំ និងគ្រប់គ្រងចាត់ចែងសកម្មភាព CPD នៅក្នុងសាលារៀននោះ ដូចជា៖

- កំណត់ពីតម្រូវការ និងធ្វើការវិភាគលើតម្រូវការ CPD
- ធ្វើផែនការ គ្រប់គ្រង និងសម្របសម្រួលសកម្មភាព CPD
- ផ្សព្វផ្សាយបញ្ជីសេវា និងចុះឈ្មោះគ្រូចូលរួមក្នុងសកម្មភាព CPD
- ជួយគ្រូក្នុងការអភិវឌ្ឍកម្រងស្នាដៃវិជ្ជាជីវៈ ដែលបង្ហាញពីសមិទ្ធផល CPD និងការឆ្លុះបញ្ចាំង
- ជួយគ្រូក្នុងការរក្សាសៀវភៅកត់ត្រាអាជីព (សៀវភៅកត់ត្រា CPD)
- សម្របសម្រួលការវាយតម្លៃគ្រូ ដូចជា រៀបចំផែនការសិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនម្នាក់ៗ និងវាយតម្លៃថាតើគ្រូបង្រៀនបានសម្រេចតាមគោលដៅ CPD របស់ខ្លួនកម្រិតណា
- សម្របសម្រួលការដឹកនាំការងារបង្រៀន (ការបង្វឹក ការផ្តល់ប្រឹក្សាគរុកោសល្យ ។ល។)
- រៀបចំការបង្រៀន និងការសង្កេតមើលគ្នាទៅវិញទៅមក/ជាក្រុម
- រៀបចំកិច្ចប្រជុំបច្ចេកទេស
- រៀបចំសិក្ខាសាលាតាមសាលារៀន ក្រោមការសម្របសម្រួលរបស់គណៈកម្មការ ឬអ្នកផ្តល់សេវា CPD ដូចជាគ្រឹះស្ថានអប់រំគ្រូ / ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ អង្គការក្រៅរដ្ឋាភិបាល
- រក្សាកំណត់ត្រាអំពីសកម្មភាព CPD ដែលបានធ្វើ និងចំនួនក្រេឌីតដែលបានទទួល
- រក្សាកំណត់ត្រាដែលបង្ហាញពីលទ្ធផលនៃការវាយតម្លៃ
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការវាយតម្លៃក្រេឌីត CPD ដែលទទួលបានជូនការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ មន្ទីរ អ.យ.ក រាជធានីខេត្ត ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS (ក្នុងករណីសាលាធំៗ

ដែលមានបរិក្ខារចាំបាច់ និងអាចភ្ជាប់អ៊ីនធឺណិតបាន គេអាចបញ្ចូលព័ត៌មាននេះទៅក្នុងប្រព័ន្ធ HRMIS ដោយផ្ទាល់ក្នុងសាលារៀន)

- ពិនិត្យតាមដាន និងវាយតម្លៃ CPD ដែលអនុវត្តនៅកម្រិតសាលារៀនជារៀងរាល់ឆ្នាំ។

គួរមានការបញ្ចូលផែនការសិក្សាវិជ្ជាជីវៈនៅកម្រិតសាលារៀនទៅក្នុងផែនការកែលម្អ ឬអភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំ។

គណៈកម្មការ CPD នៅតាមសាលារៀនគួរចងក្រងបណ្ដាញជាមួយនឹងកម្រងសាលាបឋមសិក្សា ឬបណ្ដាញវិទ្យាល័យធនធាន ដើម្បីចែករំលែកគំនិត សហការអនុវត្តសកម្មភាព និងបង្កើនប្រសិទ្ធភាពចំណាយ។ សកម្មភាព CPD មួយចំនួនត្រូវអនុវត្តនៅក្នុងកម្រងសាលាដែលផ្ដល់លទ្ធភាពឱ្យគ្រូបង្រៀន (និងនាយកសាលា) មកពីតាមសាលារៀនជាច្រើន អាចចូលរួមនៅក្នុងសកម្មភាព CPD ដែលផ្ដល់ដោយអ្នកផ្ដល់សេវាមានការទទួលស្គាល់គុណភាព និងនាយកសាលាជាច្រើននាក់អាចចូលរួម និងមានការសន្សំសំចៃថវិកា។ សកម្មភាព CPD ដែលអាចធ្វើឡើងនៅកម្រិតកម្រង រួមមាន៖

- នាយកសាលាការសហការគ្នាវាយតម្លៃពីតម្រូវការនិងការរៀបចំកម្មវិធី CPD ។ល។
- ការរៀបចំផែនការ ការគ្រប់គ្រង និងការសម្របសម្រួលសកម្មភាព CPD នៅកម្រិតកម្រង
- សិក្ខាសាលានៅតាមកម្រងដោយមានការសម្របសម្រួលពីកម្រង ឬអ្នកផ្ដល់សេវា CPD ដូចជា គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន/ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ/មន្ទីរ អ.យ.ក រាជធានីខេត្ត អង្គការក្រៅរដ្ឋាភិបាល ការិយាល័យគ្រប់គ្រង CPD)
- ការបង្វឹក និងការផ្ដល់ប្រឹក្សាគរុកោសល្យ
- ការធ្វើទស្សនកិច្ចនៅតាមសាលារៀនឬការដោះបុគ្គលិករយៈពេលខ្លីរៀនពីបទពិសោធន៍

យើងបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតសាលារៀនឬកម្រងដើម្បីផ្ដល់លទ្ធភាពឱ្យគ្រូបន្ទុកថ្នាក់ និងគ្រូឯកទេស នាយកសាលា និងអ្នកឯកទេសអប់រំ ផ្ដល់ការគាំទ្រដល់គ្នាទៅវិញទៅមកក្នុងគោលបំណងកែលម្អការបង្រៀន ការដឹកនាំ និងការអនុវត្តការងារអប់រំ។ សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន អាចបញ្ចូលសកម្មភាពបង្វឹកនិងផ្ដល់ប្រឹក្សាគរុកោសល្យដែលកំពុងអនុវត្តនៅក្នុងសាលារៀននាពេលបច្ចុប្បន្ន ឬគ្រោងអនុវត្តនាពេលអនាគត ដោយគ្រូផ្ដល់ប្រឹក្សាគរុកោសល្យនៅក្នុងសាលារៀនផ្ដល់ប្រឹក្សាគរុកោសល្យដល់គ្រូបង្រៀនដែលទើបចេញថ្មី និងផ្ដល់ការបង្វឹកដល់សហការីរបស់ខ្លួន។ សហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតកម្រងដែលផ្ដោតលើនាយកសាលា ផ្ដល់លទ្ធភាពឱ្យនាយកសាលាមកពីតាមសាលារៀនជាច្រើននៅក្នុងកម្រង អាចចែករំលែកបទពិសោធន៍ និងធនធានជាមួយគ្នា ក៏ដូចជា ជួយគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្នាទៅវិញទៅ មក។ សហគមន៍សិក្សាវិជ្ជាជីវៈគួរទទួលបានការគាំទ្រពីអ្នកផ្ដល់ប្រឹក្សាឬ គ្រូបង្វឹកនៅថ្នាក់ភូមិភាគឬ ថ្នាក់ខេត្តមានបទពិសោធន៍ ដែលគេហៅថាអ្នកផ្ដល់ប្រឹក្សាបង្គោល។

## ការិយាល័យ អ.យ.ក ក្រុង ស្រុក ខណ្ឌ

ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ ជាអ្នកសម្របសម្រួលរវាងសាលារៀន និងថ្នាក់រាជធានីខេត្ត/ជាតិ។ មន្ត្រីបង្គោលទទួលបន្ទុក CPD នៅកម្រិតការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ ជាអ្នកសម្របសម្រួលនិងការបញ្ជូនព័ត៌មានពីសាលារៀន ឬកម្រងទៅកាន់មន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត។ ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ ទទួលខុសត្រូវបំពេញតួនាទីដូចខាងក្រោម៖

- ប្រមូលទិន្នន័យ CPD និងទិន្នន័យវាយតម្លៃប្រចាំឆ្នាំពីតាមសាលារៀន និងបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS (ឬផ្ញើទៅកាន់មន្ទីរ អ.យ.ក រាជធានីខេត្ត ប្រសិនបើពុំមានសម្ភារបរិក្ខារ ដើម្បីបញ្ចូលទិន្នន័យនេះ)
- ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្របច្ចេកទេសដល់នាយកសាលា និងគណៈកម្មាធិការ CPD ក្នុងការវាយតម្លៃគ្រូបង្រៀន និងការវាយតម្លៃលើតម្រូវការ CPD និងជួយគ្រូក្នុងការគ្រប់គ្រងកម្រងស្នាដៃវិជ្ជាជីវៈ ការរក្សាសៀវភៅកត់ត្រាអាជីព និងសកម្មភាពដទៃទៀត
- ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងប្រព័ន្ធ CPD ទៅកាន់សាលារៀន និងកម្រង និងរំឭកសាលារៀន និងកម្រងអំពីនីតិវិធី និងកាលបរិច្ឆេទកំណត់ ដើម្បីចុះឈ្មោះគ្រូបង្រៀនឱ្យចូលរួមនៅក្នុងសកម្មភាព CPD
- សម្របសម្រួលសកម្មភាព CPD ដែលត្រូវបានទទួលស្គាល់គុណភាព
- ផ្តល់ការធានាគុណភាពដល់សកម្មភាព CPD
- ធ្វើការវាយតម្លៃកម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សាដល់នាយកសាលា (ដោយសម្របសម្រួលជាមួយនឹងគ្រឹះស្ថានអប់រំគ្រូទៅតាមការចាំបាច់)
- ធ្វើការពិនិត្យតាមដាន និងវាយតម្លៃលើកម្មវិធីដែលអនុវត្តនៅតាមសាលារៀន និងតាមកម្រង។

## មន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត

មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ធ្វើការស្របសម្រួលរវាងការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ និងថ្នាក់ជាតិ។ មន្ត្រីបង្គោលទទួលបន្ទុក CPD របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ជាអ្នកសម្របសម្រួល និងការបញ្ជូនព័ត៌មានរវាងការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ និងការិយាល័យគ្រប់គ្រង CPD និងទទួលខុសត្រូវបំពេញមុខងារដូចខាងក្រោម៖

- ប្រមូលទិន្នន័យ CPD និងទិន្នន័យវាយតម្លៃប្រចាំឆ្នាំពីការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ និងបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS
- ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្របច្ចេកទេសដល់មន្ត្រីបង្គោលទទួលបន្ទុក CPD របស់ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ ផ្តោតលើបញ្ហាបច្ចេកទេសនៅក្នុងប្រព័ន្ធ CPD
- ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងប្រព័ន្ធ CPD ដល់ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ រំឭកការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌអំពីនីតិវិធី និងកាលបរិច្ឆេទកំណត់សម្រាប់ចុះឈ្មោះគ្រូឱ្យចូលរួមនៅក្នុង

សកម្មភាព CPD

- គាំទ្រ និងពិនិត្យតាមដានសកម្មភាព CPD ដែលត្រូវបានទទួលស្គាល់គុណភាព
- ផ្តល់ការធានាគុណភាពដល់សកម្មភាព CPD
- ធ្វើការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី CPD នៅតាមសាលារៀន និងកម្រង នៅថ្នាក់ខេត្ត។

## ការិយាល័យគ្រប់គ្រង CPD (CPDMO) របស់ក្រសួងអប់រំ យុវជន និងកីឡា និងប្រព័ន្ធHRMIS

ការិយាល័យ CPDMO គឺជាការិយាល័យមួយក្រោមឱវាតក្រសួងអប់រំ យុវជន និងកីឡា ដែលទទួលខុសត្រូវលើការគ្រប់គ្រង ចាត់ចែង និងធ្វើលិខិតបទដ្ឋានគតិយុទ្ធគ្រប់ផ្នែកទាំងអស់នៃប្រព័ន្ធ CPD។ ការិយាល័យគ្រប់គ្រង CPD មានទីតាំងស្ថិតនៅក្នុងនាយកដ្ឋានបុគ្គលិក។ ការិយាល័យគ្រប់គ្រង CPD បែងចែកជា ៣ ផ្នែកៈ ផ្នែកកត់ត្រា និងគ្រប់គ្រងទិន្នន័យ និងក្រេឌីត CPD, ផ្នែកសម្របសម្រួល កំណត់ស្តង់ដាគោល ផ្តល់ការទទួលស្គាល់គុណភាព ផ្តល់ការធានាគុណភាព និងរៀបចំថវិកា CPD, ផ្នែកព័ត៌មាន និងផ្សព្វផ្សាយអំពី CPD។ ផ្នែកទាំង ៣ នេះ ធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយនឹងផ្នែកដែលពាក់ព័ន្ធនៃនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ។

ផ្នែកកត់ត្រា និងគ្រប់គ្រងទិន្នន័យ និងក្រេឌីត CPD ទទួលខុសត្រូវលើការរក្សាទិន្នន័យក្រេឌីត CPD ដែលគ្រូបង្រៀនបានទទួល និងរក្សាទិន្នន័យសេវា CPD (សូមមើលឧបសម្ព័ន្ធ X ស្តីពីលក្ខខណ្ឌប្រតិបត្តិរបស់ការិយាល័យគ្រប់គ្រង CPD ដែលកំណត់លម្អិតពីតួនាទីរបស់ផ្នែកទាំង ៣) ដោយប្រើប្រាស់ម៉ូឌុល CPD នៅក្នុងប្រព័ន្ធ HRMIS របស់ក្រសួងអប់រំ យុវជន និងកីឡា[៨]។ ផ្នែកនេះទទួលខុសត្រូវលើការចេញវិញ្ញាបនបត្រ CPD រៀងរាល់ ៥ ឆ្នាំម្តង ឬទៅតាមការស្នើសុំ ដោយបង្ហាញពី CPD ដែលគ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំម្នាក់ៗបានបញ្ចប់ដោយជោគជ័យ។

ផ្នែកសម្របសម្រួល កំណត់ស្តង់ដាគោល ផ្តល់ការទទួលស្គាល់គុណភាព ផ្តល់ការធានាគុណភាព និងរៀបចំថវិកា CPD ជាអង្គភាពគ្រប់គ្រង និងធ្វើបញ្ញត្តិកម្មសកម្មភាព CPD ដូចជា កំណត់ស្តង់ដាគោលនៃសេវា CPD ផ្តល់ការទទួលស្គាល់គុណភាពដល់អ្នកផ្តល់សេវា និងផលិត CPD និងផ្តល់ការធានាគុណភាព នៅគ្រប់កម្រិតទាំងអស់។ ផ្នែកគ្រប់គ្រង និងផ្សព្វផ្សាយ CPD គ្រប់គ្រងការផ្សព្វផ្សាយព័ត៌មានដល់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសផ្នែកអប់រំ ដូចជាការផ្សព្វផ្សាយបញ្ជីសេវា CPD ប្រចាំឆ្នាំដែលមានសម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ។

ការទទួលខុសត្រូវរបស់ការិយាល័យគ្រប់គ្រង CPD រួមមានៈ

[8] ប្រព័ន្ធ HRMIS ក៏គ្រប់គ្រងគន្លងអាជីពគ្រូបង្រៀនផងដែរ តាមរយៈម៉ូឌុល TCP ដែលផ្តល់លទ្ធភាពឱ្យប្រព័ន្ធផ្តល់ និងរក្សាទុកក្រេឌីត CPD នេះអាចឆ្លងឆ្លើយជាមួយនឹង TCP និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សគ្រូបង្រៀនដទៃទៀត។

- រៀបចំ អនុវត្ត និងត្រួតពិនិត្យគោលនយោបាយ និងផែនការសកម្មភាព CPD
- សម្របសម្រួល និងធ្វើការវាយតម្លៃលើតម្រូវការ CPD
- សម្របសម្រួលការទទួលស្គាល់គុណភាពសកម្មភាព និងអ្នកផ្តល់សេវា CPD (ដល់ស្ថាប័ន និងគ្រូឧទ្ទេស)
- ផលិត និងផ្សព្វផ្សាយប្រតិទិនសេវា CPD ប្រចាំឆ្នាំ
- ផ្តល់ការធានាគុណភាព CPD
- គ្រប់គ្រងចាត់ចែងការផ្តល់ថវិកា CPD នៅកម្រិតសាលារៀន
- ផ្សព្វផ្សាយ និងត្រួតពិនិត្យការចុះឈ្មោះចូលរួមនៅក្នុងសមាគមវិជ្ជាជីវៈ
- ផ្សព្វផ្សាយ និងត្រួតពិនិត្យការចុះបញ្ជីព្រឹត្តិបត្រឈ្មោះចូលរួមនៅក្នុងព្រឹត្តិបព័ត៌មាន និងព្រឹត្តិបត្រវិជ្ជាជីវៈ
- រៀបចំផលិតផល CPD សម្រាប់បុគ្គលិកអប់រំ
- ពិនិត្យតាមាន និងផ្តល់ការធានាគុណភាពដល់ការវាយតម្លៃគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំប្រចាំឆ្នាំ
- ពិនិត្យតាមដាន និងផ្តល់ការធានាគុណភាពដល់ការវាយតម្លៃសកម្មភាព CPD ដែលផ្តល់ដោយអ្នកផ្តល់សេវា CPD ដែលនាំឱ្យមានការផ្តល់ក្រេឌីត CPD។

### អ្នកផ្តល់សេវា CPD

ស្ថាប័នឬបុគ្គលមានសិទ្ធិស្នើសុំការទទួលស្គាល់គុណភាពតាមកម្រិតជំនាញផ្សេងៗគ្នា ឬអាចបំពេញតួនាទីជាដៃគូសហការក្នុងការផ្តល់សេវា CPD ក្នុងករណីស្ថាប័នឬបុគ្គលនោះ បំពេញបានតាមលក្ខខណ្ឌដូចបានកំណត់នៅក្នុងដំណើរការផ្តល់ការទទួលស្គាល់គុណភាព (សូមមើលផ្នែកទី ៤ ខាងក្រោម និងឧបសម្ព័ន្ធទី ៨)[9]។ ស្ថាប័នឬបុគ្គលទាំងនោះរួមមានៈ

- គ្រឹះស្ថានអប់រំគ្រូ
- គ្រឹះស្ថានឧត្តមសិក្សា
- នាយកដ្ឋានជំនាញរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ដៃគូអភិវឌ្ឍន៍
- អង្គការក្រៅរដ្ឋាភិបាលជាតិ
- អ្នកផ្តល់សេវា CPD ដើម្បីប្រាក់ចំណេញ
- គ្រូឧទ្ទេសអាជីព
- គ្រូមានបទពិសោធន៍ និងអ្នកឯកទេសអប់រំ

[9] តាមរយៈការប្រើប្រាស់អភិក្រមជាជំហានៗនេះ អ្នកផ្តល់សេវា CPD ដើម្បីប្រាក់ចំណេញ អ្នកបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រូជាន់ខ្ពស់ និងអ្នកអប់រំម្នាក់ៗ មានសិទ្ធិទទួលបានការទទួលស្គាល់គុណភាព ក្នុងដំណាក់កាលទី ២ ដែលអនុវត្តចាប់ឆ្នាំ ២០២៥ តទៅ។

- ជាផ្នែកមួយនៃការផ្តល់ការទទួលស្គាល់គុណភាពដល់ស្ថាប័ន គ្រូឧទ្ទេសនិងអ្នកអប់រំម្នាក់ៗដែលកំពុងបំរើការនៅក្នុងស្ថាប័នផ្តល់សេវា CPD ត្រូវតែមានបញ្ជីឈ្មោះ និងបញ្ជាក់ពីកម្រិតគុណវុឌ្ឍិរបស់ពួកគេឱ្យបានច្បាស់លាស់។

## ៣.២ ប្រព័ន្ធព័ត៌មាន CPD គន្លងអាជីពគ្រូបង្រៀន (TCP) និង HRMIS

ប្រព័ន្ធ CPD ពាក់ព័ន្ធនឹងតួអង្គ និងស្ថាប័នជាច្រើន ដែលព័ត៌មានត្រូវហូរឆ្លងកាត់ ដើម្បីឱ្យប្រព័ន្ធនេះអាចដំណើរការទៅប្រកបដោយប្រសិទ្ធភាព។ រូបទី៣ខាងក្រោមបង្ហាញពីដំណើរការនៃលំហូរព័ត៌ ដោយគ្រូបង្រៀនជាអ្នកចូលរួមធ្វើសកម្មភាព CPD ហើយក្រេឌីតបានមកពី CPD នេះត្រូវបានកត់ត្រាក្នុងប្រព័ន្ធ HRMIS និងបង្ហាញពីទំនាក់ទំនងរវាងប្រព័ន្ធ CPD និង TCP។ ប្រព័ន្ធ CPD និង TCPមានទំនាក់ទំនងគ្នាច្បាស់លាស់ ខណៈសន្សំក្រេឌីតបានពីការចូលរួមសកម្មភាព CPD ដោយជោគជ័យ ហើយវាជាលក្ខណៈវិនិច្ឆ័យមួយសម្រាប់តម្លើងឋានៈវិជ្ជាជីវៈនៅក្នុងគន្លងអាជីព។សូមអានបន្ថែម ក្របខណ្ឌ CPD និងគោលការណ៍ណែនាំអនុវត្ត ឆ្នាំ២០២១។

*រូបភាពទី ៣៖ ប្រព័ន្ធលំហូរក្រេឌីត CPD និងទំនាក់ទំនងជាមួយ TCP (ប្រភព៖ B. Khan និង S. Doctors ចម្លងចេញពីឯកសារពិពណ៌នាអំពីម៉ូឌុល CPD)*




## ប្រព័ន្ធលំហូរក្រេឌីត CPD និងទំនាក់ទំនងជាមួយ TCP

**១. គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ** គឺជាក្រុមគោលដៅនៃប្រព័ន្ធ CPD និង TCP។ ពួកគេមានសិទ្ធិ និងកាតព្វកិច្ចក្នុងការចូលរួមសកម្មភាព CPD ដែលរៀបចំដោយមានគោលបំណងច្បាស់លាស់ និងជាទៀងទាត់ ព្រមទាំងមានឱកាសដាក់ពាក្យសុំឡើងឋានៈវិជ្ជាជីវៈស្របតាមគន្លងអាជីពគ្រូបង្រៀននៅពេលដែលពួកគេបំពេញបានតាមលក្ខណៈវិនិច្ឆ័យចាំបាច់នានា។

**២. គណៈកម្មការ CPD** នៅតាមសាលារៀនត្រូវសម្របសម្រួលផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀន និងនាយកសាលា រៀបចំវាយតម្លៃលើតម្រូវការ CPD របស់គ្រូម្នាក់ៗ និងតម្រូវការ CPD នៅក្នុងសាលារៀនទាំងមូល និងត្រូវផ្សព្វផ្សាយព័ត៌មានអំពីឱកាស CPD ដោយសហការជាមួយអ្នកផ្តល់សេវា CPD។

**៣. CPD មានរចនាសម្ព័ន្ធ និង ស្វ័យ CPD កម្មវិធីវិក្រឹតការ និងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ៖** CPD អាចរៀបចំឡើងដោយអ្នកផ្តល់សេវាមានរចនាសម្ព័ន្ធច្បាស់លាស់ និង/ឬដែលសាមីខ្លួនជ្រើសរើសដោយខ្លួនឯង។ ឧទាហរណ៍អំពី CPD ដែលរៀបចំដោយអ្នកផ្តល់សេវា ឬកម្មវិធី INSET រួមមានវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា

ដែលផ្តល់ដោយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដូចជាវគ្គបណ្តុះបណ្តាលនៅក្នុង កម្មវិធីបង្កើនគុណវុឌ្ឍិគ្រូជាដើម។ ឧទាហរណ៍ពីសកម្មភាព CPD ដែលចូលរួមដោយខ្លួនឯង រួមមានការបញ្ចប់វគ្គសិក្សាអនឡាញបើកចំហ (Mass Open Online Course (MOOC)) ការអានអត្ថបទស្រាវជ្រាវ និងការសរសេររបាយការណ៍សង្ខេបស្តីពីការយកចំណេះដឹងដែលទទួលបានទៅអនុវត្តនៅក្នុងសាលារៀនផ្ទាល់ខ្លួន ការស្រាវជ្រាវប្រតិបត្តិ ឬការដឹកនាំកិច្ចប្រជុំចែករំលែកបទពិសោធនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈជាដើម។

**៤. ការទទួលក្រេឌីតពី CPD ៖ ការផ្តល់**ក្រេឌីតជូនគ្រូ នាយកសាលា ឬអ្នកឯកទេសអប់រំ បន្ទាប់ពីបានបញ្ចប់សកម្មភាព CPD ណាមួយប្រកបដោយជោគជ័យ។ អ្នកផ្តល់សេវា CPD ដែលមានការទទួលស្គាល់គុណភាព ត្រូវផ្ទៀងផ្ទាត់និងបញ្ជាក់ឱ្យបានត្រឹមចំពោះ CPD មានរចនាសម្ព័ន្ធច្បាស់លាស់ ដែលសាមីខ្លួនទទួលបាន ហើយគណៈកម្មការ CPD នៅតាមសាលារៀន ជាអ្នកផ្ទៀងផ្ទាត់លើក្រេឌីតដែលបានពីសកម្មភាព CPD ដែលសាមីខ្លួនចូលរួមឬរៀនដោយខ្លួនឯង។ ក្រេឌីតទាំងនេះត្រូវបានបញ្ចូល ទៅក្នុងកំណត់ត្រាអាជីពរបស់បុគ្គលម្នាក់ៗ និងកត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិចក្នុងប្រព័ន្ធ HRMIS។

**៥. ការវាយតម្លៃកម្រិតអង្គភាព និងគ្រឹះស្ថានសិក្សា និងលទ្ធផលប្រចាំឆ្នាំ៖** គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំទាំងអស់ត្រូវរៀបចំការវាយតម្លៃប្រចាំឆ្នាំ តាមធម្មតាជាមួយនឹងអ្នកគ្រប់គ្រងផ្ទាល់ដើម្បី វាស់វែងសមិទ្ធកម្ម(performance)ធៀបនឹងចំណុចដៅដែលបានដាក់ចេញកាលពីឆ្នាំមុន ទទួលស្គាល់ពីសមិទ្ធផល (achievement)ដែលសម្រេចបាន កំណត់ពីបញ្ហាដែលត្រូវធ្វើការកែលម្អបន្ថែម និងដើម្បីកំណត់គោលដៅ CPD សម្រាប់ឆ្នាំបន្ទាប់។ តាមការវាយតម្លៃប្រចាំឆ្នាំអ្នកទទួលបានជោគជ័យ គួរផ្តល់លាភការជាប្រព័ន្ធ។ ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ តាមដានការវាយតម្លៃជាប្រចាំ។ មន្ទីរ អ.យ.ក រាជធានីខេត្ត ពិនិត្យតាមដានការសម្របសម្រួល និងការគាំទ្ររបស់ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌដែលផ្តល់ដល់សាលារៀនក្នុងការវាយតម្លៃប្រចាំឆ្នាំ និងបញ្ចូលលទ្ធផលវាយតម្លៃ ទៅក្នុងប្រព័ន្ធ HRMIS។

**៦. ការសុំដំឡើងឋានៈវិជ្ជាជីវៈតាមគន្លងអាជីពគ្រូបង្រៀន៖** អ្នកសន្សំបានក្រេឌីតពី CPD ហើយមានទំនុកចិត្តថាពិតជាបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃឋានៈវិជ្ជាជីវៈនីមួយៗស្របតាមគន្លងអាជីពគ្រូបង្រៀន អាចដាក់ពាក្យស្នើសុំការវាយតម្លៃតម្លើងឋានៈក្នុងគន្លងអាជីពគ្រូបង្រៀន ក្រោយពីបានពិភាក្សាជាមួយនឹងអ្នកគ្រប់គ្រងផ្ទាល់។ អ្នកអនុវត្ត CPD អាចបើកមើលព័ត៌មានឬពិន្ទុបច្ចុប្បន្នភាពផ្ទាល់ខ្លួនតាមកម្មវិធីទូរស័ព្ទចល័ត (mobile application) ហើយព័ត៌មានទាំងនោះនឹងបញ្ជាក់ពីលទ្ធភាពដែលអាចទទួលបានជោគជ័យក្នុងការវាយតម្លើងឋានៈក្នុងគន្លងអាជីពគ្រូបង្រៀន ដោយផ្តោតលើលក្ខណៈវិនិច្ឆ័យចំនួន៥ សម្រាប់គ្រូ និងនាយកសាលាគឺ ១) គុណវុឌ្ឍិ ២) បទពិសោធការងារ ៣) ស្នាដៃការងារ ៤) លទ្ធផលសិក្សារបស់សិស្ស និង ៥) សមត្ថភាពវិជ្ជាជីវៈ និងលក្ខណៈវិនិច្ឆ័យចំនួន ៤ សម្រាប់អ្នកឯកទេសអប់រំគឺ ១) គុណវុឌ្ឍិ ២) បទពិសោធការងារ ៣) ស្នាដៃការងារ និង៤) សមត្ថភាពវិជ្ជាជីវៈ។

**៧. ការវាយតម្លៃក្នុងគន្លងអាជីពគ្រូបង្រៀន និងការសម្រេចចិត្ត៖** អ្នកដាក់ពាក្យសុំឡើងឋានៈវិជ្ជាជីវៈស្របតាមគន្លងអាជីពគ្រូបង្រៀន ត្រូវឆ្លងកាត់ការវាយតម្លៃ "កម្រិតខ្ពស់"។ ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌទទួលពាក្យ

សុំវាយតម្លៃ រួចបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តដើម្បីស្នើសុំការឯកភាពនិងធ្វើសំណើតម្លើងឋានៈវិជ្ជាជីវៈ ជូនទៅគណៈកម្មការCPDថ្នាក់ ជាតិ។ គណៈកម្មការCPDថ្នាក់ជាតិមានសមាសភាពជាប្រធាន ឬអនុប្រធាននាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងអំឡុងពេលនៃការវាយតម្លៃនេះ បេក្ខជន (គ្រូ នាយកសាលា ឬអ្នកឯកទេសអប់រំ) បង្ហាញភស្តុតាងបញ្ជាក់ថាពួកគេពិតជាបំពេញទៅតាមលក្ខណៈវិនិច្ឆ័យ ដើម្បីឡើងឋានៈវិជ្ជាជីវៈ ក្នុង TCP។ គណៈកម្មាធិការធ្វើការវាយតម្លៃលើពាក្យសុំ ដោយប្រើប្រាស់លក្ខណៈវិច្ឆ័យ និងបញ្ចូលលទ្ធផលវាយតម្លៃស្របតាម TCP ទៅក្នុងប្រព័ន្ធ HRMIS។ ប្រសិនបើការវាយតម្លៃនេះជោគជ័យ បេក្ខជនទទួលបានការឡើងឋានៈវិជ្ជាជីវៈទៅកម្រិតបន្ទាប់ទៀតក្នុង TCP និងឡើងប្រាក់បំណាច់ឋានៈវិជ្ជាជីវៈ។

**៨. ការមិនបំពេញបានតាមលក្ខណៈវិនិច្ឆ័យ TCP៖** ប្រសិនបើការវាយតម្លៃតម្លើងឋានៈវិជ្ជាជីវៈមិនទទួលបានជោគជ័យ នោះបេក្ខជននឹងមិនត្រូវបានឡើងឋានៈវិជ្ជាជីវៈទេ។បេក្ខជនអាចបើកមើលព័ត៌មានឬពិន្ទុបច្ចុប្បន្នភាពផ្ទាល់ខ្លួនតាមកម្មវិធីទូរស័ព្ទចល័តនឹងដឹងពីពិន្ទុរបស់ខ្លួន ហើយអាចដាក់ពាក្យសាជាថ្មីនៅឆ្នាំក្រោយ ដែលក្នុងរយៈពេលនេះ បេក្ខជនអាចខិតខំកែលម្អការបំពេញការងារ សម្រាប់ផ្នែកដែលទទួលពិន្ទុក្រោមស្តង់ដា។

**៩. សាលារៀន៖** CPD ក៏អាចរៀបចំនៅកម្រិតសាលារៀនផងដែរ មានន័យថាសកម្មភាព CPD ជាច្រើនអាចធ្វើឡើងនៅក្នុងសាលារៀនដូច្នេះ CPD ទាំងនេះគឺពាក់ព័ន្ធផ្ទាល់ជាមួយនឹងសកម្មភាព និងលទ្ធផលនៃការបំពេញការងារនៅក្នុងថ្នាក់រៀន។ ការវាយតម្លៃគ្រូបង្រៀនប្រចាំឆ្នាំត្រូវធ្វើឡើងនៅកម្រិតសាលារៀន។

**១០. កម្រងសាលារៀន៖** កម្រងសាលារៀនសម្របសម្រួលសកម្មភាព CPD ផ្តល់ការគាំទ្រដល់គ្រូតាមរយៈកម្មវិធីប្រឹក្សាគរុកោសល្យ (mentoring programmes) និងសកម្មភាព CPD ដែលផ្តល់ដោយអ្នកផ្តល់សេវា CPD ដូចជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូដែលមានការទទួលស្គាល់គុណភាពជាដើម។ កម្រងសាលារៀនបំពេញមុខងារជាអ្នកសម្របសម្រួលរវាងការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌនិងសាលារៀនដូចជាការផ្សព្វផ្សាយព័ត៌មានជូនដល់សាលារៀន និងការបញ្ជូនទិន្នន័យស្តីពី CPD របស់គ្រូម្នាក់ៗទៅកាន់ការិយាល័យ អ.យ.កក្រុងស្រុកខណ្ឌ ដែលបន្ទាប់មកត្រូវបញ្ជូនព័ត៌មាននេះបន្តទៀតទៅកាន់មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS។

**១១. ការិយាល័យ អ.យ.ក ស្រុកក្រុង៖** មានតួនាទីសំខាន់សម្រាប់ផ្តល់ព័ត៌មានពីឱកាសនិងក្រេឌីត CPD ទៅសាលារៀន ក៏ដូចជាផ្តល់ព័ត៌មានពី CPD ដែលគ្រូម្នាក់ៗបានចូលរួម និងក្រេឌីតដែលពទទួលបាន ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត។ ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌអាចតែងតាំងមន្ត្រីបង្គោល ឱ្យទទួលខុសត្រូវលើ CPD និង TCP។

**១២. មន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត៖** គ្រប់គ្រងប្រព័ន្ធ CPD និង TCP នៅថ្នាក់ក្រោមជាតិ និងជាកន្លែងតំណភ្ជាប់ទំនាក់ទំនងរវាងក្រសួងអប់រំ យុវជន និងកីឡា និងការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ។ រាជធានីខេត្តត្រូវសម្របសម្រួលគ្រប់សកម្មភាព CPD ជាផ្លូវការ។ មន្ត្រីបង្គោលរបស់មន្ទីរ អ.យ.ក រាជធានីខេត្ត ត្រូវរៀបចំ និងផ្សព្វផ្សាយប្រតិទិនពីឱកាស CPD នៅកម្រិតរាជធានីខេត្ត។ ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ បញ្ជូនទិន្នន័យ CPD និង TCP ទៅមន្ទីរ អ.យ.ក រាជធានីខេត្ត ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS។ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តអាចចាត់តាំងមន្ត្រីបង្គោលឱ្យទទួលខុសត្រូវលើការងារ CPD និង TCP។

**១៣. ការិយាល័យគ្រប់គ្រង CPD៖** គ្រប់គ្រងទិន្នន័យ CPD និង TCP ទាំងអស់នៅថ្នាក់ជាតិ រៀបចំគោលនយោបាយ CPD កំណត់ថវិកាគាំទ្រដល់សកម្មភាព CPD រាប់បញ្ចូលទាំងសកម្មភាព CPD នៅតាមសាលារៀន ផ្តល់ការទទួលស្គាល់គុណភាពដល់អ្នកផ្តល់សេវា CPD និងកម្មវិធី CPD ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីឱកាស CPD។ ការិយាល័យគ្រប់គ្រង CPD ផ្តល់ការគាំទ្រ និងសម្របសម្រួលសកម្មភាពនៅថ្នាក់ក្រោមជាតិតាមរយៈបណ្តាញរបស់ក្រសួងអប់រំ យុវជននិងកីឡារួមមាន នាយកដ្ឋានបច្ចេកទេ មន្ទីរ អ.យ.ក រាជធានីខេត្ត ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ កម្រង និងសាលារៀន។

**១៤.** HRMIS (**ម៉ូឌុល** CPD **និង** TCP)**៖** គ្រប់គ្រងរាល់ទិន្នន័យទាំងអស់ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិជ្ជាជីវៈ និងវឌ្ឍនភាពអាជីពរបស់បុគ្គលិកអប់រំ។

**១៥. ការកត់ត្រាក្រេឌីត CPD និងសៀវភៅកត់ត្រាអាជីព៖** រាល់សកម្មភាព CPD ទាំងអស់ត្រូវមានការកត់ត្រាចំនួនក្រេឌីត ប្រធានបទ ខ្លឹមសារសំខាន់ៗ និងមានការចេញផ្សាយសៀវភៅកត់ត្រាអាជីពដែលបង្ហាញពីព័ត៌មាននៃការអនុវត្ត CPD រយៈពេល ៥ ឆ្នាំម្តង ឬទៅតាមភាពចាំបាច់។

**១៦. ការឡើងឋានៈវិជ្ជាជីវៈក្នុង TCP និងការផ្តល់រង្វាន់៖** មានការកត់ត្រាទិន្នន័យអំពីគុណវុឌ្ឍិអប់រំ បទពិសោធលទ្ធផលនៃការវាយតម្លៃ និង CPD របស់បុគ្គលិកអប់រំ ដើម្បីចេញជារបាយការណ៍ដែលបង្ហាញព័ត៌មានលម្អិតស្តីពីពិន្ទុសម្រាប់ទទួលបានការឡើងឋានៈវិជ្ជាជីវៈទៅកាន់កម្រិតបន្ទាប់ក្នុងគន្លងអាជីពគ្រូបង្រៀន។

**១៧.នាយកដ្ឋានបច្ចេកទេសក្រោមចំណុះក្រសួងអយក គ្រឹះអប់រំគ្រូ គ្រឹះស្ថានឧត្តមសិក្សា និងអង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់សេវា CPD/TQU/INSETឯកជន ៖** អ្នកផ្តល់សេវា CPD មានការទទួលស្គាល់គុណភាពពីការ CPDMO មានដូចជា នាយកដ្ឋានបច្ចេកទេសក្រោមចំណុះក្រសួងអយក គ្រឹះស្ថានអប់រំគ្រូ គ្រឹះស្ថានឧត្តមសិក្សា អង្គការក្រៅរដ្ឋាភិបាល អ្នកផ្តល់សេវា CPD/INSET ឯកជន និងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនផ្សេងទៀត ជាអ្នកផ្តល់សេវា CPD ផ្លូវការអាចធ្វើបាននៅតាមកម្រិតសាលារៀន។

**១៨. ក្រុមបង្វឹក គ្រូប្រឹក្សា និងគ្រូឧទ្ទេសបង្គោលថ្នាក់ជាតិ៖ ជា**បុគ្គលដែលបំពេញបានតាមលក្ខណៈវិនិច្ឆ័យជាអ្នកផ្តល់សេវាអប់រំនិងបានការទទួលស្គាល់គុណភាពពី CPD អាចផ្តល់សេវា CPD នៅសាលារៀនដោយផ្ទាល់ឬតាមរយៈគ្រឹះស្ថានដែលជាអ្នកផ្តល់សេវា CPD ផងដែរ។

**១៩. ការទទួលស្គាល់គុណភាព ការធានាគុណភាព និងការពិនិត្យតាមដាន និងវាយតម្លៃ៖** CPDMO សហការជាមួយនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធពិសេសនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការនិងគណៈកម្មការទទួលស្គាល់គុណភាពអប់រំគ្រូជាធានាខុសត្រូវលើការទទួលស្គាល់គុណភាព ការធានាគុណភាព និងការតាមដាននិងវាយតម្លៃប្រព័ន្ធ CPD ជាពិសេស លើការផ្តល់សេវា CPD ដែលផ្តល់ដោយបុគ្គល និងជាស្ថាប័នផ្តល់សេវា CPD ។

**២០. ការកំណត់ស្តង់ដាអប្បបរមា** (Benchmarking) **ការទទួលស្គាល់គុណភាព និងក្រុមធានាគុណភាព៖** CPDMO ធ្វើការសហការជាមួយការិយាល័យពាល់ព័ន្ធរបស់នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីកំណត់ស្តង់ដាអប្បបរមាសម្រាប់ផ្តល់សេវា CPD ប្រកបដោយគុណភាព ក្នុងបរិបទប្រព័ន្ធក្រេឌីត CPD ព្រមទាំងធ្វើការបញ្ជាក់គុណភាព និងផ្តល់ការធានាគុណភាពទៅតាមស្តង់ដាអប្បបរមា។

# ៤. នីតិវិធី យន្តការទទួលស្គាល់អ្នកផ្តល់សេវា និងការផ្តល់ CPD

អ្នកផ្តល់សេវា CPD ត្រូវតែមានការទទួលស្គាល់ពី CPDMO ដើម្បីធានាឱ្យបានទៅតាមលក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់អ្នកផ្តល់សេវា CPD។ គ្រឹះស្ថាននានា (គ្រឹះស្ថានអប់រំ គ្រឹះស្ថានឧត្តមសិក្សា នាយកដ្ឋានជំនាញ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងពេលខ្លះអ្នកផ្តល់សេវា CPD ដើម្បីប្រាក់ចំណេញ) ឬបុគ្គល (ពេលខ្លះអ្នកវិជ្ជាជីវៈគ្រូឧទ្ទេស គ្រូច្នៃម និងគ្រូឧទ្ទេស) អាចទទួលបានការទទួលស្គាល់ជាអ្នកផ្តល់សេវា CPD ក្នុងករណីបំពេញបានតាមលក្ខណៈវិនិច្ឆ័យដែលតបានកំណត់សម្រាប់ដំណើរការផ្តល់ការទទួលស្គាល់គុណភាព។

## ៤.១ គ្រឹះស្ថាន និងដំណើរការ

### .៤.១.១ ការទទួលស្គាល់គ្រឹះស្ថានផ្តល់សេវានិងការផ្តល់CPD

*គណៈកម្មការសម្រាប់ពិនិត្យ វាយតម្លៃ និង ផ្តល់ការទទួលស្គាល់គុណភាពគ្រឹះស្ថាន និងអ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ* មានសមាសភាពមកពីថ្នាក់ដឹកនាំក្រសួង អ.យ.ក តំណាងគណៈកម្មាធិការទទួលស្គាស់គុណភាពអប់រំនៃកម្ពុជា(ACC) និងតំណាងមកពីនាយកដ្ឋានពាក់ព័ន្ធជាអ្នកផ្តល់សិទ្ធិអនុញ្ញាឱ្យស្ថាប័នផ្តល់សេវា និងបុគ្គលផ្តល់សេវា CPD ដំណើរការសិក្ខាសាលាឬវគ្គបំប៉នផ្សេងៗ។ CPDMO ជាអ្នកដើរតួដ៏សំខាន់ក្នុងការបំពេញមុខងារគ្រប់គ្រងចាត់ចែងផ្តល់ការទទួលស្គាល់គុណភាពជាប្រចាំ។នាយកដ្ឋានជំនាញពាក់ព័ន្ធ CPDMO និង ACC សហការរៀបចំនិងប្រើប្រាស់ លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់គុណភាព ឧបករណ៍ និងនិតិវិធី សម្រាប់ផ្តល់ការទទួលស្គាល់គុណភាព។*គណៈកម្មការសម្រាប់ពិនិត្យ វាយតម្លៃ និង ផ្តល់ការទទួលស្គាល់គុណភាពគ្រឹះស្ថាន និងអ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ* ពិសេស CPDMO មានសិទ្ធិអញ្ជើញតំណាងស្ថាប័នផ្តល់សេវា និងបុគ្គលផ្តល់សេវា CPD មកបំភ្លឺពីការដាក់ពាក្យសុំស្នើវាយតម្លៃទទួលស្គាល់គុណភាពឬបើកវគ្គCPDក្នុងករណីមិនយល់។

### ៤.១.២ នីតិវិធីទទួលស្គាល់គុណភាព

ការដាក់ពាក្យសុំការទទួលស្គាល់គុណភាពជាអ្នកផ្តល់សេវាឬបើកវគ្គ CPD អាចចម្លងចេញទម្រង់ពាក្យស្នើសុំពី វេបសាយរបស់ CPDMO (ឧបសម្ព័ន្ធ៨)រួចបំពេញព័ត៌និងបញ្ជូនទៅ CPDMO ដោយមានភស្តុតាងគាំទ្រគ្រប់គ្រាន់។ អ្នកដាក់ពាក្យស្នើសុំគួរតែត្រូវពិភាក្សាជាមួយអង្គភាពសាមីមុនពេលបំពេលពាក្យសុំដើម្បីធានាឱ្យបំពេញបានលក្ខណៈវិនិច្ឆ័យទទួលស្គាល់គុណភាពនិងមានភស្តុកតាងជាក់លាក់ហើយទទួលខុសត្រូវពន្យល់ពីវិធីដែលភស្តុតាងគាំទ្រសម្រេចបានលក្ខណៈវិនិច្ឆ័យ(អាចពន្យល់បន្ថែមលើសន្លឹកផ្សេងទៀតបើចាំពាច់)។ក្នុងករណីមានភស្តុតាងជាទម្រង់ឯកសារច្រើនទំព័រ គួរតែបញ្ជាក់ពីផ្នែកដែលពាក់ព័ន្ធ និងលេខរៀងទំព័រ។បន្ទាប់ពីការពិនិត្យពាក្យស្នើសុំនិងភស្តុតាងដោយប្រើឧបករណ៍ពាក់ព័ន្ធ(ឧបសម្ព័ន្ធ៨) បុគ្គលិក CPDMO នឹងអញ្ជើញ

អ្នកដាក់ពាក្យស្នើសុំឬក៏សុំផ្តល់ភ័ស្តុតាងបន្ថែមក្នុងករណីចាំបាច់តែបើពិនិត្យឃើញថាបានបំពេញលក្ខខណ្ឌសព្វគ្រប់ហើយ CPDMO នឹងបញ្ជូនទៅ*គណៈកម្មការសម្រាប់ពិនិត្យ វាយតម្លៃ និង ផ្តល់ការទទួលស្គាល់គុណភាពគ្រឹះស្ថាន និងអ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ*ដើម្បីលទ្ធផលចុងក្រោយ។រយៈពេលនៃការផ្តល់លទ្ធផលស្នើសុំការទទួលស្គាល់គុណភាពគឺ៦០ថ្ងៃគិតចាប់ពីពេលស្នើសុំដោយមានភ័ស្តុតាងគ្រប់គ្រាន់។រូបទី៤ខាងក្រោមបង្ហាញពីដំណាក់នៅក្នុងនីតិវិធីទទួលស្គាល់គុណភាព។

**រូបទី៤: នីតិវិធីទទួលស្គាល់គុណភាព**




## ៤.២ ការទទួលស្គាល់គុណភាពគ្រឹះស្ថានផ្តល់សេវា CPD

អ្នកផ្តល់សេវា CPD ទទួលខុសត្រូវដាក់ពាក្យទៅកាន់ការិយាល័យគ្រប់គ្រង CPD ដើម្បីសុំការទទួលស្គាល់គុណភាព ដោយត្រូវដាក់សំណើអមជាមួយនឹងភស្តុតាងពាក់ព័ន្ធសម្រាប់គាំទ្រដល់សំណើរបស់ខ្លួន។ ពាក្យសុំនេះមានទម្រង់ជាលិខិត ឬអ៊ីមែល ដោយបង្ហាញពីមូលហេតុដែលខ្លួនស្នើសុំការទទួលស្គាល់គុណភាពជាអ្នកផ្តល់សេវា CPD ឬសុំការទទួលស្គាល់គុណភាពដល់សេវា CPD របស់ខ្លួន និងបង្ហាញភស្តុតាងដែលបញ្ជាក់ពីការគោរពតាមលក្ខណៈវិនិច្ឆ័យ ដើម្បីទទួលបានការទទួលស្គាល់គុណភាព (សូមមើលឧបករណ៍ផ្តល់ការទទួលស្គាល់គុណភាពនៅក្នុងឧបសម្ព័ន្ធទី ៨)។ ការយាល័យគ្រប់គ្រង CPD ត្រូវពិនិត្យលើពាក្យសុំ និងត្រូវធ្វើការងារជាមួយនឹងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីពិនិត្យមើផ្នែកដែលពាក់ព័ន្ធទៅតាមការចាំបាច់ និងធ្វើការឆ្លើយតបឱ្យបានទាន់ពេលវេលា។

អាចមានការសម្រេចចិត្តចំនួន ៣ ប្រភេទ៖

- ផ្តល់ការទទួលស្គាល់គុណភាព
- ការទទួលស្គាល់គុណភាពត្រូវបានផ្តល់ជាបណ្តោះអាសន្ន ដោយរង់ចាំពិនិត្យមើលការកែលម្អចំណុចជាក់លាក់មួយចំនួន
- បដិសេធមិនផ្តល់ការទទួលស្គាល់គុណភាព

នៅក្នុងករណីមួយៗ ត្រូវមានការជម្រាបជូនអ្នកដាក់ពាក្យសុំពីការសម្រេចចិត្តនេះឱ្យបានទាន់ពេលវេលា។

នៅក្នុងករណីដែលមានការផ្តល់ការទទួលស្គាល់គុណភាព ឬផ្តល់ការទទួលស្គាល់គុណភាពជាបណ្តោះអាសន្ន បេក្ខជនត្រូវបញ្ចូលការសម្រេចចិត្ត ("បានទទួលការទទួលស្គាល់គុណភាពពេញលេញ ដើម្បីផ្តល់សេវា CPD ដល់គ្រូ" ឬ "បានទទួលស្គាល់គុណភាពជាបណ្តោះអាសន្ន ដើម្បីផ្តល់សេវា CPD ដល់គ្រូ"[10]) ក្នុងសកម្មភាពផ្សព្វផ្សាយទាំងអស់របស់ពួកគេ (ដូចជានៅក្នុងក្បាលលិខិត ផ្ទាំងប៉ាណូផ្សព្វផ្សាយ ។ល។)។ ក្នុងករណីដែលមានការផ្តល់ការទទួលស្គាល់គុណភាពជាបណ្តោះអាសន្ន ការផ្សព្វផ្សាយត្រូវបញ្ចូលព័ត៌មានលម្អិតអំពីការកែលម្អដែលចាំបាច់ និងក្របខណ្ឌពេលវេលាដែលត្រូវធ្វើការកែលម្អទាំងនេះ ដែលជាធម្មតា មានរយៈពេល ៣ ឆ្នាំ។ បេក្ខជនអាចផ្តល់សេវា CPD នៅក្នុងរយៈពេលនេះបាន ហើយក្រោយរយៈពេលនេះពួកគេត្រូវដាក់ពាក្យសុំឡើងវិញ ដោយបង្ហាញភស្តុតាងដែលបញ្ជាក់ពីការបំពេញទៅតាមលក្ខណៈវិនិច្ឆ័យដែលនៅមិនទាន់បានបំពេញកន្លងមក។ ពាក្យសុំថ្មីអាចនាំឱ្យមានការផ្តល់ការទទួលស្គាល់គុណភាព (ប្រសិនបើមានការបំពេញទៅតាមគ្រប់លក្ខណៈវិនិច្ឆ័យទាំងអស់) ឬការផ្តល់ការទទួលស្គាល់គុណភាពអាចនៅជាបណ្តោះអាសន្នម្តងទៀត ដោយរង់ចាំការកែលម្អបន្ថែម (ប្រសិនបើចាំបាច់ត្រូវមានការកែលម្អបន្ថែម) និងមានការប្រកាសពីក្របខណ្ឌពេលវេលាថ្មី ដើម្បីបំពេញទៅតាមលក្ខខណ្ឌទាំងនេះ។ បេក្ខជនអាចបន្តផ្តល់ CPD នៅក្នុងរយៈពេលនេះបាន ដែលក្រោយរយៈពេលនេះ ពួកគេត្រូវដាក់ពាក្យសុំថ្មី ដែលបង្ហាញភស្តុតាងពីការបំពេញទៅតាមលក្ខណៈវិនិច្ឆ័យដែលនៅមិនទាន់បានបំពេញ។ បេក្ខជនដែលនៅមិនទាន់បានបំពេញតាមលក្ខណៈវិនិច្ឆ័យនៅពេលដាក់ពាក្យសុំជាលើកទី ៣ នឹងពុំទទួលបានការទទួលស្គាល់គុណភាពឡើយ ហើយលែងអាចផ្តល់សេវា CPD បានទៀត។

ក្នុងករណីដែលមានការបដិសេធមិនផ្តល់ការទទួលស្គាល់គុណភាព ឯកសារទំនាក់ទំនងត្រូវបញ្ចូលព័ត៌មានលម្អិតអំពីមូលហេតុដែលនាំឱ្យមានការបដិសេធ បេក្ខជនអាចដាក់ពាក្យសុំការទទួលស្គាល់គុណភាពជាថ្មី មួយឆ្នាំក្រោយមក។ ពាក្យសុំនាពេលអនាគតអាចបញ្ចូលភស្តុតាងដែលរៀបរាប់ពីការឆ្លើយតបចំពោះបញ្ហាដែលនាំឱ្យមានការបដិសេធមិនផ្តល់ការទទួលស្គាល់គុណភាព។

ឧបករណ៍ដែលបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ៨ អាចយកមកប្រើប្រាស់សម្រាប់ការទទួលស្គាល់គុណភាពដល់អ្នកផ្តល់សេវា CPD ជាស្ថាប័ន។ ឧបករណ៍ទាំងនេះត្រូវបានរៀបចំឡើងផ្អែកតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ ២០១០, ស្តង់ដាវិជ្ជាជីវៈនាយកសាលា (២០១៧), និងស្តង់ដាអ្នកផ្តល់សេវាអប់រំគ្រូឆ្នាំ ២០១៦ (TEPS), ក្របខណ្ឌសមត្ថភាពគ្រូបង្រៀននៅអាស៊ីអាគ្នេយ៍ឆ្នាំ ២០១៨, ក្របខណ្ឌសមត្ថភាពគ្រូបង្រៀនអាស៊ីអាគ្នេយ៍សម្រាប់សតវត្សរ៍ទី ២១ និងស្តង់ដាសមត្ថភាពគ្រូសម្រាប់ប្រទេសនៅអាស៊ីអាគ្នេយ៍ឆ្នាំ ២០១០ (សូមមើលឧបសម្ព័ន្ធ ៨)[11]។

[10] ឬ "បានទទួលការទទួលស្គាល់គុណភាពពេញលេញ ដើម្បីអាចផ្តល់សេវា CPD ជូនគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ" ឬ "បានទទួលការទទួលស្គាល់គុណភាពបណ្តោះអាសន្ន ដើម្បីអាចផ្តល់សេវា CPD ជូនគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ"ទៅតាមការសមស្រប។

[11] ក្របខណ្ឌ និងផែនការសកម្មភាព CPD បញ្ជាក់យ៉ាងច្បាស់ថា ប្រហែលជាចាំបាច់ត្រូវកែសម្រួលស្តង់ដាអ្នកផ្តល់សេវាអប់រំគ្រូ

## ៤.៣ ការផ្តល់ការទទួលស្គាល់គុណភាពដល់គ្រូឧទ្ទេស

គ្រូឧទ្ទេសម្នាក់ៗដែលត្រូវបានបំពេញការងារឱ្យអ្នកផ្តល់សេវា CPD ដែលត្រូវបានទទួលស្គាល់គុណភាព ត្រូវមានឈ្មោះនៅក្នុងពាក្យសុំការទទួលស្គាល់គុណភាពដែលដាក់ដោយអ្នកផ្តល់សេវា។ ពាក្យសុំនេះត្រូវបង្ហាញព័ត៌មានលម្អិតពីសាវតារវិជ្ជាជីវៈ គុណវុឌ្ឍិ និងបទពិសោធន៍វិជ្ជាជីវៈរបស់ពួកគេ។ នៅក្នុងដំណើរការផ្តល់ការទទួលស្គាល់គុណភាព ប្រហែលជាអាចមានការតម្រូវឱ្យបង្កើនគុណវុឌ្ឍិរបស់គ្រូឧទ្ទេសដែលពុំបានបំពេញទៅតាមលក្ខខណ្ឌ (ជាផ្នែកមួយនៃការផ្តល់ការទទួលស្គាល់គុណភាពជាបណ្តោះអាសន្ន) ឬជំនួសគ្រូឧទ្ទេសទាំងនេះដោយគ្រូឧទ្ទេសដែលមានសមត្ថភាពជាង។

## ៤.៤ ការផ្តល់ការទទួលស្គាល់គុណភាពដល់សេវា CPD

រាល់សកម្មភាព CPD ទាំងអស់ដែលផ្តល់ដោយអ្នកផ្តល់សេវា CPD ត្រូវតែឆ្លងកាត់ការទទួលស្គាល់គុណភាព។ សកម្មភាព CPD ដែលត្រូវបានទទួលស្គាល់គុណភាពជាបណ្តោះអាសន្ន អាចផ្តល់ឱ្យបានក្នុងរយៈពេលដែលអនុញ្ញាតឱ្យផ្តល់ ដើម្បីរង់ចាំការបំពេញលក្ខខណ្ឌនានា (សូមមើល ៤.១ ខាងលើ)។ ប្រព័ន្ធ HRMIS សកម្មភាព CPD ឬសេវា CPD ដែលត្រូវបានទទួលស្គាល់គុណភាពដែលអាចផ្តល់ដោយអ្នកផ្តល់សេវានីមួយៗ។ ព័ត៌មានទាំងនេះមាននៅក្នុងបញ្ជីសេវា សកម្មភាព CPD ឬសេវា CPD ប្រចាំឆ្នាំដែលការិយាល័យគ្រប់គ្រង CPD ត្រូវចែកជូនសាលារៀន និងផ្សព្វផ្សាយដល់គ្រូបង្រៀនតាមរយៈអ៊ែបនៅក្នុងទូរសព្ទ។

ឧបសម្ព័ន្ធទី ៨ បង្ហាញពីឧបករណ៍ដែលប្រើប្រាស់ សម្រាប់ផ្តល់ការទទួលស្គាល់គុណភាពដល់សេវា CPD។

អ្នកផ្តល់សេវា CPD ត្រូវដាក់ទៅកាន់ការិយាល័យគ្រប់គ្រង CPD ដើម្បីស្នើសុំការទទួលស្គាល់គុណភាពដល់សេវា CPD នីមួយ ដោយត្រូវដាក់សំណើ និងឯកសារគាំទ្រដែលពាក់ព័ន្ធ។ ការយាល័យគ្រប់គ្រង CPD ត្រូវពិនិត្យលើពាក្យសុំ និងត្រូវធ្វើការងារជាមួយនឹងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីពិនិត្យមើផ្នែកដែលពាក់ព័ន្ធទៅតាមការចាំបាច់ និងធ្វើការឆ្លើយតបឱ្យបានទាន់ពេលវេលា។ បេក្ខជននឹងទទួលបានការជូនដំណឹងអំពីការសម្រេចចិត្ត ហើយត្រូវបញ្ចូលការសម្រេចនេះ ("សេវា CPD បានទទួលការទទួលស្គាល់គុណភាពពេញលេញ" ឬ "សេវា CPD បានទទួលស្គាល់គុណភាពជាបណ្តោះអាសន្ន") ក្នុងសកម្មភាពផ្សព្វផ្សាយរបស់ខ្លួន (ខិត្តបណ្ណ គេហទំព័រ បញ្ជីសេវា CPD ។ល។)។

---

(TEPS) សម្រាប់គោលបំណងនេះ (19)។ ប៉ុន្តែ ការកែសម្រួល TEPS អាចស្ថិតនៅក្រៅវិសាលភាពនៃការងាររបស់ UNESCO ដូច្នេះ ឧបករណ៍ដែលស្នើឡើងនេះ ត្រូវបានរៀបចំឡើងផ្អែកតាម TEPS បច្ចុប្បន្ន។

អាចមានការសម្រេចចិត្តចំនួន ៣ ប្រភេទ៖

- ផ្តល់ការទទួលស្គាល់គុណភាព
- ការទទួលស្គាល់គុណភាពត្រូវបានផ្តល់ជាបណ្តោះអាសន្ន ដោយរង់ចាំពិនិត្យមើលការកែលម្អចំណុចជាក់លាក់មួយចំនួន
- បដិសេធមិនផ្តល់ការទទួលស្គាល់គុណភាព

នៅក្នុងករណីមួយៗ ត្រូវមានការជម្រាបជូនអ្នកដាក់ពាក្យសុំពីការសម្រេចចិត្តនេះឱ្យបានទាន់ពេលវេលា។

នៅក្នុងករណីដែលមានការផ្តល់ការទទួលស្គាល់គុណភាពជាបណ្តោះអាសន្ន ព័ត៌មានផ្សព្វផ្សាយត្រូវបញ្ចូលព័ត៌មានលម្អិតអំពីការកែលម្អដែលចាំបាច់ និងក្របខណ្ឌពេលវេលាដែលត្រូវបំពេញទៅតាមលក្ខខណ្ឌកែលម្អទាំងនេះ។ បេក្ខជនអាចផ្តល់សេវា CPD នៅក្នុងរយៈពេលនេះបាន ដែលក្រោយរយៈពេលនេះពួកគេត្រូវដាក់ពាក្យសុំថ្មី អមដោយភស្តុតាងដែលបង្ហាញពីការបំពេញទៅតាមលក្ខណៈវិនិច្ឆ័យ ដែលមិនទាន់បានបំពេញកន្លងមក។ ពាក្យសុំថ្មីអាចនាំឱ្យមានការផ្តល់ការទទួលស្គាល់គុណភាព (ប្រសិនបើមានការបំពេញទៅតាមគ្រប់លក្ខណៈវិនិច្ឆ័យទាំងអស់) ឬការផ្តល់ការទទួលស្គាល់គុណភាពអាចផ្តល់ជាបណ្តោះអាសន្នម្តងទៀត ដោយរង់ចាំការកែលម្អបន្ថែម (ប្រសិនបើការកែលម្អបន្ថែមជារឿងដែលចាំបាច់) និងមានការប្រកាសផ្តល់ពេលបន្ថែមទៀត ដើម្បីឱ្យបំពេញទៅតាមលក្ខខណ្ឌទាំងនេះ។ សេវា CPD អាចបន្តផ្តល់នៅក្នុងរយៈពេលនេះ ដែលក្រោយពីរយៈពេលនេះអ្នកផ្តល់សេវាត្រូវដាក់ពាក្យសុំថ្មី អមជាមួយនឹងភស្តុតាងដែលបង្ហាញពីការបំពេញតាមលក្ខណៈវិនិច្ឆ័យដែលពុំទាន់បានបំពេញកន្លងមក។ សេវា CPD ដែលពុំបានបំពេញតាមលក្ខខណ្ឌនៅពេលដែលដាក់ពាក្យសុំជាលើកទី ៣ នឹងពុំអាចទទួលបានការទទួលស្គាល់គុណភាពទៀតឡើយ ហើយគេក៏លែងអាចផ្តល់សេវា CPD នេះទៀត។

ក្នុងករណីដែលមានការបដិសេធមិនផ្តល់ការទទួលស្គាល់គុណភាព ឯកសារទំនាក់ទំនងត្រូវបញ្ចូលព័ត៌មានលម្អិតអំពីមូលហេតុដែលនាំឱ្យមានការបដិសេធ បេក្ខជនអាចដាក់ពាក្យសុំការទទួលស្គាល់គុណភាពជាថ្មីមួយឆ្នាំក្រោយមក។ ពាក្យសុំនាពេលអនាគតអាចបញ្ចូលភស្តុតាងដែលរៀបរាប់ពីការឆ្លើយតបចំពោះបញ្ហាដែលនាំឱ្យមានការបដិសេធមិនផ្តល់ការទទួលស្គាល់គុណភាព។

## ៤.៥ ការអនុវត្តស្តង់ដារអប្បបរមា

ការរៀបចំសេវា ឬសកម្មភាព CPD ត្រូវបំពេញទៅតាមតម្រូវការវិជ្ជាជីវៈរបស់គ្រូបង្រៀន និងនាយកសាលា ដែលជាក្រុមគោលដៅនៃសេវា ឬសកម្មភាព CPD ទាំងនេះ។ ប្រព័ន្ធក្រេឌីត CPD រៀបរាប់លម្អិតអំពីការកំណត់ស្តង់ដារជាគោលសម្រាប់ CPD ដែលរៀបចំសម្រាប់គ្រូបង្រៀននៅកម្រិតនីមួយៗ (គ្រូបង្រៀនដែលមាន

បំណងចង់បង្កើនគុណវុឌ្ឍិរបស់ខ្លួនដល់កម្រិតបរិញ្ញាបត្រអប់រំ គ្រូថ្មើម គ្រូឈានមុខ គ្រូល្អ) និងនាយកសាលា និងអ្នកឯកទេសអប់រំនៅគ្រប់ដំណាក់កាលទាំងអស់នៃអាជីពរបស់ពួកគេ។ ស្តង់ដាគោលទាំងនេះចាំបាច់ត្រូវយកទៅអនុវត្ត ដើម្បីឱ្យមានការប្រើប្រាស់ស្តង់ដាគោលទាំងនេះប្រកបដោយប្រសិទ្ធភាព និងងាយស្រួល ដើម្បីផ្តល់ការទទួលស្គាល់គុណភាពដល់សេវា CPD និងការធានាគុណភាព។ ការអនុវត្តស្តង់ដាគោលតម្រូវឱ្យមានការបំប្លែងសេចក្តីពិពណ៌នាដែលមានលក្ខណៈអរូបី ដូចជា សេចក្តីពិពណ៌នាអំពីចំណេះដឹង និងសមត្ថភាពឱ្យទៅជាសេចក្តីពិពណ៌នាឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងដែលអាចយកទៅប្រើប្រាស់ ដើម្បីវាយតម្លៃផ្តល់សេវា CPD ឬសេវា CPD ឧទាហរណ៍នៅក្នុងក្របខណ្ឌនៃឧបករណ៍វាយតម្លៃទទួលស្គាល់គុណភាពណាមួយ។

# ៥. ព័ត៌មាន និងការផ្សព្វផ្សាយដល់គ្រូបង្រៀន និងនាយកសាលា

ប្រព័ន្ធ CPD គឺជាវិធីសាស្ត្រមួយថ្មី ដើម្បីបន្តផ្តល់ការគាំទ្រដល់ការអប់រំគ្រូ ដោយចាត់ទុកគ្រូបង្រៀន ឬនាយកសាលាម្នាក់ៗជាស្នូលនៃដំណើរការនេះ។ ប្រព័ន្ធនេះតម្រូវឱ្យមានការផ្លាស់ប្តូរវប្បធម៌ និងការផ្សព្វផ្សាយឱ្យបានច្បាស់លាស់ពីគោលបំណង គោលដៅ និងយន្តការរបស់ប្រព័ន្ធ។ ដូច្នេះហើយបានជាការនៅក្នុងការិយាល័យគ្រប់គ្រង CPD មានផ្នែកមួយដែលទទួលខុសត្រូវលើការផ្តល់ព័ត៌មាន និងផ្សព្វផ្សាយ។

## ៥.១ ផ្សព្វផ្សាយអំពី CPD

ផ្នែកព័ត៌មាន និងផ្សព្វផ្សាយជាអង្គភាពថែទាំគេហទំព័រ និងកម្មវិធីតាមទូរសព្ទដៃរបស់ការិយាល័យគ្រប់គ្រង CPD ដែលជាប្រភពផ្តល់ព័ត៌មានបច្ចុប្បន្នភាពពី CPD និងផ្សព្វផ្សាយព័ត៌មានអំពីប្រព័ន្ធ CPD ដល់គ្រូបង្រៀន និងនាយកសាលាតាមរយៈមន្ត្រីបង្គោលរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត និងការិយាល័យ អ.យ.ក និងកីឡាក្រុងស្រុកខណ្ឌ។ ព័ត៌មានដែលផ្សព្វផ្សាយតាមបែបនេះ រួមមាន៖

- សៀវភៅណែនាំ CPD ជាទម្រង់ក្រដាស និងអេឡិចត្រូនិក
- ប្រតិទិនដែលបង្ហាញពីសកម្មភាព CPD ប្រចាំឆ្នាំ
- សមាគមវិជ្ជាជីវៈ និងព្រឹត្តិបត្រ/ទិនានុប្បវត្តិ
- នាពេលអនាគត នឹងមានការផ្សព្វផ្សាយប្រភពជាតុចូលសម្រាប់ CPD ដែលចូលរួមដោយខ្លួន ដោយមានការទទួលស្គាល់គុណភាព
- ឯកសារសម្ភារបង្កើនការយល់ដឹងអំពី CPD
- បញ្ជីសហគមន៍សិក្សាវិជ្ជាជីវៈ ដែលគេអាចចូលរួម ដើម្បីទទួលបានក្រេឌីត CPD
- គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងឯកសារ CPD ដូចជា សៀវភៅកត់ត្រា CPD ផែនការសិក្សាវិជ្ជាជីវៈ កម្រងស្នាដៃវិជ្ជាជីវៈ ។ល។

## ៥.២ ដំណើរការ CPD តាមប្រព័ន្ធអនឡាញ

ការិយាល័យគ្រប់គ្រង CPD មានគេហទំព័រមួយដែលគ្រូបង្រៀន និងនាយកសាលាអាចចូលមើលដោយផ្ទាល់ រួមទាំងតាមរយៈកម្មវិធីក្នុងទូរសព្ទដៃផងដែរ។ គេហទំព័រនេះផ្តល់លទ្ធភាពឱ្យគ្រូបង្រៀន និងនាយកសាលា អាចបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រង និងការធ្វើផែនការអភិវឌ្ឍន៍វិជ្ជាជីវៈរបស់ពួកគេ និងគាំទ្រដល់ការឡើងឋានៈវិជ្ជាជីវៈរបស់ពួកគេ។ តាមរយៈគេហទំព័រ ឬកម្មវិធីក្នុងទូរសព្ទនេះ គ្រូបង្រៀន និងនាយកសាលាអាច៖

- ចូលទៅមើលកម្រងព័ត៌មានរបស់ពួកគេ ដូចជា ព័ត៌មានអំពីគុណវុឌ្ឍិ បទពិសោធន៍វិជ្ជាជីវៈ លទ្ធផលនៃការវាយតម្លៃ និងក្រេឌីត CPD ជាដើម។
- ផ្ទៀងផ្ទាត់ព័ត៌មានអំពីពួកគេ និងដាក់សំណើសុំឱ្យមានការកែតម្រូវទៅតាមការសមស្រប ធ្វើត្រាប់ការគណនាពិន្ទុ TCP ដើម្បីបញ្ជាក់ផ្ទៀងផ្ទាត់របស់ពួកគេ ធៀបនឹងការឡើងឋានៈវិជ្ជាជីវៈស្របតាមគន្លងអាជីពគ្រូបង្រៀន ដើម្បីធ្វើការសម្រេចចិត្តអំពីពេលដែលសមស្រប ដើម្បីស្នើសុំឱ្យមានការវាយតម្លៃ TCP។
- ស្នើសុំវិញ្ញាបនបត្រ CPD ដែលរៀបរាប់លម្អិតពី CPD ដែលពួកគេបានចូលរួមប្រកបដោយជោគជ័យនៅក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ឬទៅតាមការចាំបាច់។
- ពិនិត្យមើលប្រតិទិនសេវា CPD ទៅតាមកម្រិតមុខវិជ្ជា ឬតំបន់ភូមិសាស្ត្រ និងចុះឈ្មោះចូលរួមនៅក្នុងសកម្មភាព CPD ជាក់លាក់។

# ឯកសារយោង

Gathumbi, A.W., Mungai, N.J. & Hintze, D.L. (2013). "Towards Comprehensive Professional Development of Teachers: The Case of Kenya". *International Journal of Process Education*, Volume 5, Issue 1.

MoEYS. (2010). Teacher Professional Standards (2010). Phnom Penh: MoEYS

MoEYS. (2011) Competency Standards for Directors of Teacher Training Colleges.
Phnom Penh: MoEYS.

MoEYS. (2016) Teacher Education Provider Standards. Phnom Penh:
MoEYS MoEYS. (2017) School Director Professional Standards. Phnom
Penh: MoEYS

MoEYS. (2019). Continuous Professional Development Framework for Teachers and School
Directors.
Phnom Penh: MoEYS

SEA-TCF. (2018) Southeast Asia Teachers Competency Framework. Teachers' Council of Thailand, Bangkok, Thailand.

SEAMEO. (2009) Competency Framework for Southeast Asian Teachers of the 21st
Century.
Philippines: SEAMEO INNOTECH

SIREP. (2010) Teacher Competency Standards in Southeast Asian Countries. Philippines: SEAMEO INNOTECH

# ឧបសម្ព័ន្ធ

## ១. ឧបករណ៍វាយតម្លៃតម្រូវការ CPD សម្រាប់គ្រូបង្រៀន

**គោលដៅ៖** ដើម្បីជួយកំណត់ និងរៀបចំសកម្មភាព CPD សំដៅលើកកម្ពស់សមត្ថភាពរបស់គ្រូបង្រៀន កម្រងសំណួរមួយត្រូវបានរៀបចំឡើងដើម្បីវាយតម្លៃលើតម្រូវការអភិវឌ្ឍន៍វិជ្ជាជីវៈរបស់អ្នក។ សូមបំពេញកម្រងសំណួរនេះដោយយកចិត្តទុកដាក់ដោយស្មោះត្រង់ និងរៀងៗខ្លួន។ ផ្អែកតាមលទ្ធផលនៃការអង្កេតនេះ នឹងមានការផ្តល់អនុសាសន៍អំពីសកម្មភាព CPD និងមានការរៀបចំ ឬស្វែងរកឱកាស CPD ដើម្បីឆ្លើយតបចំពោះតម្រូវការទាំងនេះ។

**សម្គាល់៖** សូមបំពេញកម្រងសំណួរនេះ និងផ្ញើមកវិញឱ្យបានត្រឹមថ្ងៃទី ............. កម្រងសំណួរនេះត្រូវការពេលប្រមាណ ២០ នាទី ដើម្បីបំពេញ។

ឈ្មោះសាលារៀន .........................................ប្រភេទសាលារៀន៖ បឋមសិក្សា / មធ្យមសិក្សា (សូមគូសរង្វង់ជុំវិញ)

ឈ្មោះគ្រូបង្រៀន៖ ............................................................. យេនឌ័រ៖ ស្រី / ប្រុស (សូមគូសរង្វង់ជុំវិញ)

គុណវុឌ្ឍិខ្ពស់បំផុត.......................................................................................................

មុខវិជ្ជាឯកទេស .............................................................................................................

មុខវិជ្ជាដែលអ្នកបង្រៀន / នឹងបង្រៀន..............................................................................

មុខវិជ្ជា ឬប្រធានបទដែលអ្នកគិតថា អ្នកត្រូវការការបណ្តុះបណ្តាលបន្ថែម៖

(១) .................................................................................................................................

(២) .................................................................................................................................

ចំនួនឆ្នាំបង្រៀន ................................................................................................

**ផ្នែក ក**

តើអ្នកគិតថា អ្នកចាំបាច់ត្រូវបង្កើនចំណេះដឹង និងជំនាញជុំវិញប្រធានបទណាមួយក្នុងចំណោមប្រធានបទខាងក្រោមដែរឬទេ? (សូមជ្រើសរើសចម្លើយរហូតដល់ ៦, ពោលគឺអាទិភាពចំនួន ៣ និងអ្វីដែលចង់រៀនចំនួន ៣)

| ប្រធានបទ ចំណេះដឹង ឬជំនាញវិជ្ជាជីវៈ | អាទិភាព | អ្វីដែលចង់រៀន |
|---|---|---|
| ការគ្រប់គ្រងថ្នាក់រៀន | | |
| ការកត់ត្រាការរីកចម្រើនរបស់សិស្ស និងការវាយតម្លៃជាប្រចាំ | | |
| វិធីសាស្ត្របង្រៀនកុមារមជ្ឈមណ្ឌល | | |
| ការរៀនសូត្របែបរុករក | | |

| | | |
|---|---|---|
| ការអប់រំបរិយាបន្ន | | |
| អំណានថ្នាក់ដំបូង | | |
| គណិតវិទ្យាថ្នាក់ដំដូង | | |
| ទំនាញសួរ | | |
| ភាសាខ្មែរ | | |
| ភាសាអង់គ្លេស | | |
| ការប្រាស្រ័យទាក់ទងជាមួយមាតាបិតាសិស្ស និងគ្រួសារសិស្ស | | |
| ការប្រើប្រាស់បច្ចេកវិទ្យា ICT សម្រាប់ថ្នាក់រៀន | | |
| ជំនាញអ៊ីនធឺណែត | | |
| ការស្រាវជ្រាវខ្នាតតូច | | |
| ការអភិវឌ្ឍបញ្ញារបស់កុមារ | | |
| ការបង្កើតសម្ភាររៀនសូត្រ | | |
| ការបង្រៀនតាមរយៈរឿង និងរឿងព្រេង | | |
| ការបង្រៀននៅក្នុងបរិយាកាសដែលមានធនធានតិចតួច | | |

**ផ្នែក ខ**

តើចំណេះដឹង ឬជំនាញដទៃទៀតណាខ្លះ ដែលអ្នកចង់អភិវឌ្ឍន៍បន្ថែមទៀត?

..................................................................................................................................................

..................................................................................................................................................

**ផ្នែក គ (ត្រូវបំពេញដោយប្រធានក្រុម)**

ផ្នែកបន្ថែមដែលប្រធានក្រុមចាត់ទុកថាចាំបាច់ត្រូវមានការអភិវឌ្ឍវិជ្ជាជីវៈ៖

..................................................................................................................................................

..................................................................................................................................................

យោបល់របស់ប្រធានក្រុមពាក់ព័ន្ធនឹងជំនាញ និងចំណេះដឹងដែលគ្រូកំណត់ថាត្រូវការការភិវឌ្ឍវិជ្ជាជីវៈ៖

..................................................................................................................................................

..................................................................................................................................................

ហត្ថលេខាគ្រូ ................................ ហត្ថលេខាប្រធានក្រុម....................................

ឈ្មោះគ្រូ .................................. ឈ្មោះប្រធានក្រុម ..........................................

## ២ ឧបករណ៍វាយតម្លៃតម្រូវការ CPD សម្រាប់នាយកសាលា

**គោលដៅ៖** ដើម្បីជួយកំណត់ និងរៀបចំសកម្មភាព CPD សំដៅលើកកម្ពស់សមត្ថភាពរបស់នាយកសាលា កម្រងសំណួរមួយត្រូវបានរៀបចំឡើងដើម្បីវាយតម្លៃលើតម្រូវការអភិវឌ្ឍន៍វិជ្ជាជីវៈរបស់អ្នក។ សូមបំពេញកម្រងសំណួរនេះរៀងៗខ្លួនដោយយកចិត្តទុកដាក់ និងដោយស្មោះត្រង់។ ផ្អែកតាមលទ្ធផលនៃការអង្កេតនេះ នឹងមានការផ្តល់អនុសាសន៍អំពីសកម្មភាព CPD និងមានការរៀបចំ ឬស្វែងរកឱកាស CPD ដើម្បីឆ្លើយតបចំពោះតម្រូវការទាំងនេះ។

**សម្គាល់៖** សូមបំពេញកម្រងសំណួរនេះ និងផ្ញើមកវិញឱ្យបានត្រឹមថ្ងៃទី ............. កម្រងសំណួរនេះត្រូវការពេលប្រមាណ ២០ នាទី ដើម្បីបំពេញ។

ឈ្មោះសាលារៀន ………………………………………ប្រភេទសាលារៀន៖ បឋមសិក្សា / មធ្យមសិក្សា (សូមគូសរង្វង់ជុំវិញ)

ឈ្មោះនាយកសាលា៖ ………………………………………………………… យេនឌ័រ៖ ស្រី / ប្រុស (សូមគូសរង្វង់ជុំវិញ)

គុណវុឌ្ឍិខ្ពស់បំផុត…………………………………………………………………………………………………

គុណវុឌ្ឍិក្នុងតួនាទីជាអ្នកគ្រប់គ្រងសាលារៀន………………………………………………………………………

មុខវិជ្ជាឯកទេស ………………………………………………………………………………………………….

មុខវិជ្ជាដែលអ្នកបង្រៀន / នឹងបង្រៀន……………………………………………………………………………..

មុខវិជ្ជា ឬប្រធានបទដែលអ្នកគិតថា អ្នកត្រូវការការបណ្តុះបណ្តាលបន្ថែម៖

(១) ……………………………………………………………………………………………………………

(២) ……………………………………………………………………………………………………………

ចំនួនឆ្នាំបង្រៀន ……………………………………………………………………………………

ចំនួនឆ្នាំដែលកាន់តួនាទីជាអ្នកគ្រប់គ្រងសាលារៀន…………………………………………………………

### ផ្នែក ក

តើអ្នកគិតថា អ្នកចាំបាច់ត្រូវបង្កើនចំណេះដឹង និងជំនាញជុំវិញប្រធានបទណាមួយក្នុងចំណោមប្រធានបទខាងក្រោមដែរឬទេ? (សូមជ្រើសរើសចម្លើយរហូតដល់ ៦, ពោលគឺអាទិភាពចំនួន ៣ និងអ្វីដែលចង់រៀនចំនួន ៣)

| **ប្រធានបទ ចំណេះដឹង ឬជំនាញវិជ្ជាជីវៈ** | **អាទិភាព** | **អ្វីដែលចង់រៀន** |
|---|---|---|
| ចំណេះដឹងអំពីក្រមសីលធម៌វិជ្ជាជីវៈ | | |
| ការដឹកនាំសាលារៀន | | |

| | | |
|---|---|---|
| ការប្តេជ្ញាចិត្តចំពោះសាលារៀន គ្រូបង្រៀន និងសិស្ស | | |
| ការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ | | |
| ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន | | |
| ការរៀបចំ និងអនុវត្តចក្ខុវិស័យ និងផែនការសកម្មភាព | | |
| ស្វ័យវាយតម្លៃ និងការគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួន | | |
| ការគ្រប់គ្រងរដ្ឋបាលសាលារៀន | | |
| ការគ្រប់គ្រងការគាំទ្រ និងការវាយតម្លៃបុគ្គលិក | | |
| ការគាំទ្រហិរញ្ញវត្ថុ | | |
| ការដឹកនាំ និងគ្រប់គ្រងការបង្រៀន និងរៀន | | |
| ការដឹកនាំ និងការគាំទ្រដល់កម្មវិធីសិក្សា | | |
| ការស្រាវជ្រាវ | | |
| ការគ្រប់គ្រងក្រុម និងការគាំទ្រដល់ដល់ការអភិវឌ្ឍវិជ្ជាជីវៈ | | |
| អធិការកិច្ចផ្ទៃក្នុង | | |
| ការភ្ជាប់ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ | | |
| បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ | | |
| ភាសាអង់គ្លេស | | |
| បន្ថែមប្រធានបទផ្សេងទៀតទៅតាមការចាំបាច់ | | |

**ផ្នែក ខ**

តើចំណេះដឹង ឬជំនាញដទៃទៀតណាខ្លះ ដែលអ្នកចង់អភិវឌ្ឍន៍បន្ថែមទៀត?

..................................................................................................................................................

..................................................................................................................................................

**ផ្នែក គ (ត្រូវបំពេញដោយប្រធានក្រុម)**

ផ្នែកបន្ថែមដែលប្រធានក្រុមចាត់ទុកថាចាំបាច់ ត្រូវមានការអភិវឌ្ឍវិជ្ជាជីវៈ៖

..................................................................................................................................................

..................................................................................................................................................

យោបល់របស់ប្រធានក្រុមពាក់ព័ន្ធនឹងជំនាញ និងចំណេះដឹងដែលគ្រូកំណត់ថាត្រូវការការភិវឌ្ឍវិជ្ជាជីវៈ៖

..................................................................................................................................................

..................................................................................................................................................

ហត្ថលេខានាយកសាលា............................. ហត្ថលេខាប្រធានក្រុម.........................................

ឈ្មោះនាយកសាលា .................................. ឈ្មោះប្រធានក្រុម .........................................

## ៣. កម្រងស្នាដៃវិជ្ជាជីវៈ

### ពិពណ៌នាពីកម្រងស្នាដៃវិជ្ជាជីវៈ និងឧទាហរណ៍ពីខ្លឹមសារនៃកម្រងស្នាដៃវិជ្ជាជីវៈ

កម្រងស្នាដៃវិជ្ជាជីវៈប្រមូលភស្តុតាងពីការអភិវឌ្ឍវិជ្ជាជីវៈ និងស្នាដៃវិជ្ជាជីវៈរបស់គ្រូនៅក្នុងរយៈពេលមួយ[12]។ កម្រងស្នាដៃវិជ្ជាជីវៈអនុញ្ញាតឱ្យយើងធ្វើការឆ្លុះបញ្ចាំងពីអ្វីដែលយើងធ្វើ ចងក្រងទុកជាឯកសារអំពីការអនុវត្តដែលយើងបានបន្តធ្វើ និងបង្ហាញពីចំណុចទាំងនេះទៅកាន់អ្នកដទៃទៀត ដូចជា សហការី និងអ្នកគ្រប់គ្រងជាដើម។

កម្រងស្នាដៃវិជ្ជាជីវៈសម្រាប់អាជីពបង្រៀន គឺជាការកត់ត្រាដ៏ប្រុងប្រយ័ត្នពីការអភិវឌ្ឍ និងស្នាដៃវិជ្ជាជីវៈនៅក្នុងរយៈពេលណាមួយ។ កម្រងស្នាដៃវិជ្ជាជីវៈ អាចបញ្ចូលចំណុចដូចខាងក្រោម៖

### ព័ត៌មានសាវតារ

- ប្រវត្តិរូប
- ព័ត៌មានសាវតារអំពីគ្រូ និងបរិបទនៃការបង្រៀន
- ទស្សនវិជ្ជាអប់រំ និងគោលដៅនៃការបង្រៀន

### ការប្រមូលចងក្រងទុកជាឯកសារពីសម្ភារឧបទ្ទេស និងការឆ្លុះបញ្ចាំងពីការបង្រៀន ឬពីសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈនៅក្នុងរយៈពេលណាមួយ

- ការរៀបរាប់ជាទូទៅអំពីគោលដៅរបស់មេរៀន និងផែនការបង្រៀនសម្រាប់មេរៀនអ្វីមួយ
- បញ្ជីរាយនាមធនធានដែលត្រូវបានប្រើប្រាស់នៅក្នុងមេរៀន
- កិច្ចតែងការបង្រៀនពីរជាប់គ្នា
- វីដេអូដែលថតការបង្រៀន
- ឧទាហរណ៍ពីការងាររបស់សិស្ស
- ការវាយតម្លៃលើការងាររបស់សិស្ស
- មូលវិចារឆ្លុះបញ្ចាំងរបស់គ្រូ
- កំណត់ហេតុនៃការបង្រៀន និងការឆ្លុះបញ្ចាំង
- មេរៀន/ការងាររបស់សិស្សបន្ថែមទៀតទៅតាមការសមស្រប

### ព័ត៌មានវិជ្ជាជីវៈ និងសម្ភារឯកសារដែលបានប្រើប្រាស់កន្លងមក

- បញ្ជីសកម្មភាពវិជ្ជាជីវៈ/អភិវឌ្ឍន៍វិជ្ជាជីវៈ
- គម្រោងស្រាវជ្រាវ (ភស្តុតាង និងឯកសារ)

[12] ដងស្រង់ចេញពី Scholastic.com

- សម្ភារឯកសារដែលបានរៀបចំ
- ការវាយតម្លៃជាផ្លូវការ ឬតារាងសង្កេតមើលការបង្រៀន
- បទបង្ហាញ
- ការវាយតម្លៃ
- គម្រោងដែលត្រូវបានផលិតឡើងសម្រាប់ការវាយតម្លៃសកម្មភាព CPD (របាយការណ៍ កំណត់ត្រា ឯកសារបង្រៀន ផ្ទាំងរូបភាព ។ល។)
- វិញ្ញាបនបត្របង្ហាញពីការបញ្ចប់/ការចូលរួម
- លិខិតផ្ដល់អនុសាសន៍

កម្រងស្នាដៃវិជ្ជាជីវៈអាចមានទម្រង់ និងខ្លឹមសារខុសៗគ្នា ប៉ុន្តែជាធម្មតាមានផ្ទុកនូវសម្ភារឯកសារដែលធ្លាប់ប្រើប្រាស់នៅក្នុងការបង្រៀនកន្លងមក ក៏ដូចជា សំណេរឆ្លុះបញ្ចាំង។ សម្ភារឯកសារដែលធ្លាប់ប្រើប្រាស់កន្លងមក ដូចជា កិច្ចតែងការបង្រៀន និងគំរូការងាររបស់សិស្ស ឬព្រឹត្តិបត្រព័ត៌មានសម្រាប់មាតាបិតា ត្រូវបញ្ចូលដោយមានសរសេរពន្យល់អមផងដែរ។ សូមសរសេរឱ្យបានជាក់លាក់បែបឆ្លុះបញ្ចាំង។ វាគឺជាការវាយតម្លៃប្រកបដោយការគិតល្អិតល្អន់ ដែលគួរបង្ហាញឱ្យឃើញតាមរយៈសម្ភារឯកសារទាំងនេះ។

សម្ភារឯកសារនីមួយៗគួរមានអមមកជាមួយនូវការរៀបរាប់ដោយសង្ខេប ដូចជា ការសេរជាសេចក្ដីពិពណ៌នាខ្លីៗជាដើម។ ឧទាហរណ៍៖

- ឈ្មោះសម្ភារឯកសារ
- កាលបរិច្ឆេទផលិត
- ការរៀបរាប់ពីបរិបទ
- គោលបំណង ការវាយតម្លៃ ឬប្រភេទមូលវិចារផ្សេងទៀត

## យោបល់បន្ថែម

- ពន្យល់ពីទស្សនវិជ្ជាអប់រំ និងគោលដៅនៃការបង្រៀនរបស់អ្នក ។
- ជ្រើសរើសលក្ខណៈជាក់លាក់នៃកម្មវិធីបង្រៀនរបស់អ្នកសម្រាប់ចងក្រងទុកជាឯកសារ។
